សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា
KhmerPost USA
E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 978-942-1641

Free

មាតិការរឿង Issue 192 11th. Jan21th. 2016

១-រដ្ឋាភិបាលទីក្រុងឡូវែល.................................០៣
២-មូលនិធិភ្នំដងរែកបើកម្ពោធនៅក្រុងឡូវែល............០៤
៣-គណៈកម្មាធិការសាលារៀនទីក្រុងឡូវែល............០៦
៤-បង្ហាញផែនការសុខភាពរបស់ TUFTS..............០៩
៥-១២យ៉ាងជួយរក្សាទុកទឹកប្រាក់ដែលអ្នកឈ្នះ.............១២
៦-កសិករខ្មែរនៅរដ្ឋ "ផ្លរីដា"..............................១៣
៧-រមណីយដ្ឋានត្រាវកុជិ....................................២៤
៨-វិធីផាត់មុខបែបធម្មជាតិ..................................២៧

**Office:** Tel: (978) 677-7163 Fax: (978) 677-7092
45 Merrimack St. Suite 218A Lowell, MA 01852

## វិចារណកថា

## ចូលឆ្នាំ២០១៦នៅអូឡិនដូ



ប៉ុណ្ណារ៉ូ

**ដោយ ប៉ុណ្ណារ៉ូ**

ខ្ញុំអាយុជិត៦ឆ្នាំហើយ ថ្ងៃទី៣១ធ្នូ ២០១៥ ពុកម៉ែឱ្យខ្ញុំទៅកំសាន្តនៅ "អូឡិនដូ"នៃរដ្ឋ"ផ្លរីដា" គឺជាកន្លែងដែលខ្ញុំបានប៉ងប្រាថ្នាយូរមកហើយ ដោយបានឃើញទីកន្លែងនោះ តាមទូរស្សន៍ គួរឱ្យសប្បាយពន់ពេកណាស់។ នាថ្ងៃចុងបញ្ចប់នៃឆ្នាំចាស់ ខ្ញុំក៏បានទៅដល់"ពិភពសមុទ្រ Sea world" រៀបចំតាមរបៀប "ឌីស្នេវើល DisneyWorld"ធ្វើឱ្យខ្ញុំនឹងកុមារឯទៀតៗចូលចិត្តជាទីបំផុត។

ពុកម៉ែខ្ញុំ ដែលនាំខ្ញុំទៅទីនោះ បានរង់ចាំដើរចូលកំសាន្តតាមជួររំលេចចម្ងាយ៣-៤ម៉ោង ពីព្រោះថ្ងៃនោះជាថ្ងៃ

**តទៅទំព័រទី ០៨**

# ពិធីសម្ពោធគណៈក្រុមប្រឹក្សាក្រុងឡូវែល

**ដោយ ម៉ែរី ធី.**

ថ្ងៃចន្ទទី៤មករា២០១៦ ពិធីសម្ពោធ សមាជិកក្រុមប្រឹក្សាក្រុងដែលបានជាប់ឆ្នោត កាលពីខែវិច្ឆិកា២០១៥ បានប្រព្រឹត្តទៅនៅសាលាក្រុង។ ស្មៀនក្រុង ម៉ាយកិល ហ្គេរី បានអានកំណត់ហេតុពីការបោះឆ្នោតនៅក្នុងនោះមានបញ្ចូលសមាជិកថ្មី គឺ ជីម ឡេរី ។ **តទៅទំព័រទី ០៩**

## City Council Inauguration

**By Mary Tautas**

On Monday, January 4th, the ceremony to announce the Lowell city council members elected in November, 2015 took place at City Hall. City Clerk Michael Geary read

**Continued to Page 09**



លោក អ៊ែត វើកគេណឺឌី ឡើងកាន់តំណែងជាអភិបាលក្រុងឡូវែល

ការិយាល័យច្បាប់
ចំម៉ាសស្ដាលីអាណូស
Law Office of Thomas Stylianos
978-459-5000
មានបទពិសោធន៍២៥ឆ្នាំ
យើងបម្រើធ្វើតាក់សម្រាប់លោកអ្នក
ការិយាល័យយើងខ្ញុំ បើកទាំងពេលយប់ និងចុងសប្ដាហ៍(រដូវធ្វើតាក់)
287 Appleton Street. Lowell MA 01852



REMEDIUM PHARMACY
ឱសថស្ថានរ៉ឹមីឌៀម
2 Vinal Square. North Chelmsford, MA 01863
ជាឱសថស្ថានបំរើការគ្រប់យ៉ាងដល់អ្នក
• ផ្ទេរឬផ្លាស់ប្ដូរសេវាកម្ម • ការវេចខ្ចប់ឱសថ
• ការលាយផ្សំឱសថ • បញ្ជូនឱសថដល់ផ្ទះដោយឥតគិតថ្លៃ
• ជួយធ្វើសំបុត្រទិញថ្នាំ • ផ្លាស់ប្ដូរយោបល់ដោយរាក់ទាក់
ឱសថស្ថានយើងខ្ញុំនិយាយភាសាខ្មែរ
FREE daily delivery | Blisterpack Packaging | Compounding Medication
Friendly consultations | Easy Transfers
Tel: 978-251-7070 | Fax: 978-251-7071

CENTURY PHARMACY & OPTICAL
937 Gorham St ALL MAJOR INSURANCES ACCEPTED Tel: 978-455-6554
ឱសថស្ថានសេនជូរី :
យើងជាអ្នកបំរើលោកអ្នកយ៉ាងប្រសើរ!



‣ ផ្ដល់សេវាដល់ទីលំនៅ
‣ ខ្ចប់ឱសថតាមបំណង
‣ ជាឱសថស្ថានដែលលោកអ្នកអាចជឿជាក់ក្នុងចិត្ត
937 Gorham St Lowell, MA, 01852
លេខទូរស័ព្ទ 978-455-6554 / លេខហ្វាក់ 978-455-9476

ការិយាល័យ មេធាវី
ចំមាស ស្ដាលីយ៉ាណូស
Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852
• Immigration •អន្តោប្រវេសន៍
• Auto Crash •គ្រោះថ្នាក់រថយន្ត
• Divorce •លែងលះប្ដីប្រពន្ធ
សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766

# CENTURY PHARMACY & OPTICAL

937 Gorham St ALL MAJOR INSURANCES ACCEPTED Tel: 978-455-6554

យើងជា
ឱសថ
ស្ថានមួយ
ដែលអាចផ្តល់
ភាពជឿជាក់
ដល់គ្រួសារ
លោកអ្នក



យើងខ្ញុំ
សូមជូនពរ
មហាប្រសើរ
ដល់លោក
អ្នក

- យើងខ្ញុំមានផ្តល់សេវាបំរើការជូនឱសថដល់ទីលំនៅ ។
- យើងខ្ញុំទទួលកាតម៉ាសហ៊ារ, និងកាតធានារ៉ាប់រង សុខភាពផ្សេងៗទៀត
- សេវាបំរើការល្អ,អតិថិជនមានភាពជឿជាក់ ។
- យកចិត្តទុកដាក់លើបញ្ហាផ្ទាល់ខ្លួននៃអតិថិជនរាល់រូប ។
- វេចខ្ចប់ឱសថសមតាមបំណងនៃអតិថិជន ។
- មានផលិតកម្មពិសេសរបស់អូធីស៊ីជារៀងរាល់ខែ ។
- យើងខ្ញុំទទួលការផ្សំថ្នាំតាមបទបញ្ជាជូនដល់អស់លោកអ្នក ។

ជាឱសថស្ថានមួយអាចផ្តល់ភាពជឿជាក់ដល់គ្រួសារអ្នក ។






យើងខ្ញុំនិយាយភាសាខ្មែរ ។

លេខទូរស័ព្ទ 978-455-6554

លេខហ្វាក់ 978-455-9476

937 Gorham St Lowell, MA, 01852

# រដ្ឋាភិបាលទីក្រុងឡូវែល

**បកប្រែដោយ : តារាយុទ្ធ**

ទីក្រុងឡូវែលមានគំរោង E មួយដែលបង្កើតឡើងដោយរដ្ឋាភិបាលអ្នកបោះឆ្នោតបានបោះឆ្នោតឱ្យក្រុមប្រឹក្សាប្រាំបួនអ្នកឱ្យជាប់ឆ្នោតរយៈពេល២អាណត្តិ។

ក្រុមប្រឹក្សាក្រុងបានតែងតាំងសមាជិក២នាក់ មួយនាក់ធ្វើជាអនុប្រធាន មួយនាក់ទៀតធ្វើជាប្រធាន។

នឹងមានមុខងារដ៏សំខាន់បីរដែរ នឹងត្រូវតែងតាំងដោយក្រុមប្រឹក្សាក្រុង។

អ្នកគ្រប់គ្រងបញ្ជីក្រុងដែលអនុម័តចំណាយនឹងកត់ត្រានូវកិច្ចការផ្នែកហិរញ្ញវត្ថុ។

អ្នកកត់ត្រាដែលថែរក្សាទុកនូវកំនត់ត្រាជំនួញរបស់មន្ត្រីទាំងអស់។

អ្នកគ្រប់គ្រងដែលមើលខុសត្រូវទៅលើការអភិវឌ្ឍន៏របស់ទីក្រុង។

**មុខងាររបស់ក្រុមប្រឹក្សាក្រុង**

**១-**ឆ្លើយតបទៅនឹងប្រជាជនដែលត្រូវការជំនួយ ឬក៏ចង់ដឹងអំពីព័តិមាន។

**២-**បញ្ចេញមតិលើបញ្ហាផ្នែកហិរញ្ញវត្ថុ ដូចជា គំរោងថវិកា ការកំញ្ចីប្រាក់ Grant Bond issue នឹងការទទួលនឹងលក់នូវដីធ្លី។

**៣-**ការបញ្ចេញមតិលើបញ្ហាតំបន់ នឹងការគ្រប់គ្រងចរាចរណ៏។

**៤-**ការបញ្ចេញមតិលើច្បាប់ ឬបទបញ្ជា

**៥-**គួសបញ្ជាក់សមាជិកក្រុមប្រឹក្សាភិបាលសំរាប់អង្គការសាធារាណៈផ្សេងៗទៀត។

តើវាមានន័យដូចម្តេចចំពោះអ្នកក្នុងនាមជាប្រជាជននៃទីក្រុងឡូវែល?

**១-**ឆ្លើយតបទៅនឹងប្រជាជនដែលត្រូវការជំនួយ ឬក៏ចង់ដឹងអំពីព័តិមាន។

**ត្រូវការឧទាហរណ៏នូវទីនេះ**

**២-**បញ្ចេញមតិលើបញ្ហាផ្នែកហិរញ្ញវត្ថុ ដូចជា គំរោងថវិកា ការកំញ្ចីប្រាក់ ជំនួយ Bond issue នឹងការទទួលនឹងលក់នូវដីធ្លី។

**តទៅទំព័រទី ១០**




# Lowell City Government

Lowell has a Plan E form of government.

Voters elect nine councilors who serve for two terms.

Councilors elect one of the members to serve as mayor and one to serve as vice chair.

There are three major positions that are appointed by the City Council.

City Auditor who approves, pays, and records all financial transactions.

City Clerk who keeps all records of official City business.

City Manager who oversees the running of the City.

**What City Councilors Do**

**1.** Respond to citizens who need information or help.

**2.** Vote on financial matters such as budgets, loans, grants, bond issues, and land acquisitions and sales.

**3.** Vote on zoning issues and traffic control issues.

**4.** Vote on ordinances or laws.

**5.** Confirm trustees and board members for various public organizations.

What does this mean to you as a citizen of Lowell?

**1.** Respond to citizens who need information or help.

**Need an example here.**

**2.** Vote on financial matters such as budgets, loans, grants, bond issues, and land acquisitions and sales.

Budgets include how much is to be spent on schools, police, fire and public safety, among other things.

**3.** Vote on zoning issues and traffic control issues.

Zoning laws affect the quality of our neighborhoods. Traffic control issues make it easier or more difficult to move from one place to another. They also affect traffic safety.

**4.** Vote on ordinances or laws.

The City Council approves, and can change, laws affecting many aspects of our daily lives. Here is a list of some of the areas of law controlled by the Council.

**Adult establishments**
Advertising
Alarm systems
Ambulances
Animals
Bicycles, skateboards and roller skates
Building construction
Buildings, dangerous
Canvassers and solicitors
Curfew
Electrical standards
Fees
Fire prevention
Graffiti
Hawkers and peddlers
Health and sanitation
Housing standards
Junk and secondhand dealers
Licenses and permits
Noise
Parks and recreation
Pawnbrokers
Peace and good order
Property maintenance
Soft drink establishments
Streets and sidewalks
Swimming pools
Taxicabs and liveries
Trees
Vehicles and traffic
Waste and recycling
Water and sewers
Wetlands
Zoning

**5.** Confirm trustees and board members for various public organizations.

Some of these organizations include the library, council on aging, hunger and homelessness commission, immigration assistance commission, commission on disability, and more.



# មូលនិធិភ្នំដងរែកបើកសម្ពោធនៅក្រុងឡូវែលរដ្ឋម៉ាសាឈូសេត

**ដោយ : ណារេត មួង**

**ឡូវែលរដ្ឋម៉ាសាឈូសេតៈ** នៅថ្ងៃសៅរ៍ ទី២៣ ខែមករា ឆ្នាំ២០១៦ មូលនិធិភ្នំដងរែកនឹងបើកសម្ពោធជាផ្លូវការ។ កម្មវិធីសម្ពោធនេះ នឹងប្រព្រឹត្តទៅនៅភោជនីយដ្ឋានសំពៅមាស នៅអគារលេខ៤៥០ Chelmsford Street, Lowell, MA 01851 ។ កម្មវិធីចែកចេញជាពីរវគ្គ។ មួយវគ្គធ្វើនៅព្រឹកដោយនិមន្តព្រះសង្ឃតាមបណ្តាវត្តនៅទីក្រុងឡូវែល មកសូត្រមន្ត និងមានពិធីរាប់បាត្រពីម៉ោង៨ព្រឹក ដល់ម៉ោង ១១:៣០ ថ្ងៃត្រង់។ វគ្គទីពីរ ចាប់ផ្តើមពីពេលយប់ម៉ោង ៦ ដល់ ម៉ោង ១២កណ្តាលអធ្រាត្រ។

កម្មវិធីពេលយប់ចាប់ផ្តើមដោយមតិស្វាគមន៍របស់លោក ជុំ ឈាង ប្រធានមូលនិធិភ្នំដងរែក។ សមាជិកស្ថាបនិកជាច្រើនរូប របស់មូលនិធិភ្នំដងរែកនឹងធ្វើបទបង្ហាញអំពីសវតារនៃការកកើតមូលនិធិភ្នំដកវែក និងស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋដែលជាអតីតជនភៀសខ្លួននៅតំបន់ភ្នំដងរែក និងវត្ថុបំណងនៃមូលនិធិនេះ។ អតីតអភិបាល ក្រុងឡូវែល និងអភិបាលក្រុងថ្មីត្រូវបានអញ្ជើញឱ្យចូលរួមក្នុងកម្មវិធីនេះ នឹងថ្លែងសំណេះសំណាលជាមួយបងប្អូនក្នុងសហគមន៍ខ្មែរផងដែរ។

ពិធីផ្លូវការនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៦ មានគោលបំណងធំៗបី :

**១-**បើកសម្ពោធមូលនិធិភ្នំដងរែកជាផ្លូវការ

**២-**អបអរសារទរការជាប់ឆ្នោតជាក្រុមប្រឹក្សាក្រុងឡូវែល

**៣-** អបអរបុណ្យចូលឆ្នាំថ្មីឆ្នាំសាកល

ថ្មីៗនេះ ក្រោមការដឹកនាំរបស់លោក ជុំ ឈាង ក្រុមការងារ Task Force ១៦ ត្រូវបានបង្កើតឡើង ដើម្បីជួយរៀបចំកម្មវិធីសម្ពោធផ្លូវការរបស់មូលនិធិភ្នំដងរែកឱ្យបានជោគជ័យ។ ក្រុមការងារនេះមានសមាជិក១១នាក់។ សមាជិកនៃក្រុមការងារទាំងអស់សុទ្ធតែជាអ្នកស្ម័គ្រចិត្ត។ សមាជិកនីមួយៗមានភារកិច្ច និងតួនាទីខុសៗគ្នា។ លោក ជុំ ឈាង ជាប្រធានក្រុម, លោកស្រី បុប្ផា ពៅ ជាជំនួយការផ្នែកសម្របសម្រួល, លោក បូរ៉េត ស៊ឹម ជាជំនួយការផ្នែករដ្ឋបាល, លោក ថារ៉ា រស់ ជាអ្នកសម្របសម្រួលផ្នែកវត្តអារាម, លោក ខេមរា កៃ និង លោកស្រី សុបិន ពិន ជាអ្នកសម្របសម្រួលមន្ត្រីមូលដ្ឋាន និងសហគមន៍, លោកស្រី លក្ខិណា សាធុការប៉ូលី និងលោកស្រី ចម្ប៉ា ប៉ង់ អ្នកសម្របសម្រួលផ្នែកអាជីកម្មមូលដ្ឋាន និងផ្នែកទីផ្សារ, លោក ណារ៉េត មួង ជាអ្នកនាំពាក្យ និងផ្សព្វផ្សាយ, អ្នកនាង នារីរ័ត្ន ម៉ម ជាអ្នកចាត់ចែងខាងផ្នែករៃអង្គាសប្រាក់ និងរៀបចំកម្មវិធី, អ្នកនាង ស្រីពេញ ពេជ្រ ជាអ្នកចាត់ចែងផ្នែកគណនេយ្យ។

មូលនិធិភ្នំដងរែកជាអង្គការមិនរកប្រាក់កម្រៃបង្កើតឡើងដើម្បីជួយកាត់បន្ថយភាពក្រីក្រ



គណកម្មាធិការរៀបចំសម្ពោធមូលនិធីភ្នំដងរែក



ឧត្តមសេនីយ៍ ឈុំ ឈាង
ប្រធានមូលនិធិ

ក្នុងចំណោមប្រជាពលរដ្ឋនៅតំបន់ឥសាន្ត (ជាប់ព្រំដែនខ្មែរ-ថៃ)។ គោលបំណងចម្បងនេះមូលនិធីនេះ គឺដើម្បីដោះស្រាយបញ្ហាដែលជាឫសគល់នៃភាពក្រីក្រ និងជួយជម្រុញឱ្យប្រជាពលរដ្ឋក្រីក្រទាំងនោះមានលទ្ធភាពចេះជួយខ្លួនឯង។ មូលនិធិនេះជួយដល់ប្រជាពលរដ្ឋក្រីក្រនៅទីជនបទ។ អង្គការនេះបង្កើតឡើងដោយក្រុមប្រឹក្សានាយកដែលមានសិទ្ធិសម្រេចដោយឯករាជ្យ។ ប្រាក់ឧបត្ថម្ភដល់អង្គការត្រូវប្រមូលមកពីសាធារណជនទូទៅ និងបានមកពីការរៃអង្គាសប្រាក់ និងជំនួយឧបត្ថម្ភជាថវិកា និងជំនួយគ្រោង។ អង្គការនេះមិនប្រកាន់និន្នាការនយោបាយមិនប្រកាន់សាសនា និងមិនលម្អៀងទៅរកក្រុមសង្គម ឬក្រុមបក្សនយោបាយណាមួយឡើយ។

សមាជិកស្ថាបនិក និងក្រុមប្រឹក្សានាយក ដែលរួមគ្នាបង្កើតមូលនិធិភ្នំដងរែករួមមានៈ លោក ជុំ ឈាង ប្រធាន, លោកស្រី បុប្ផា ពៅ ប្រធានក្រុមប្រឹក្សានាយក, លោក បូរ៉េត ស៊ឹម ហិរញ្ញិក, លោក ថារ៉ា រស់ លេខាធិការ, លោក សាត មហោរី, លោក វណ្ណា សុក, លោក អែនឌ្រូ ផិនឌុលថុន អ្នកគ្រប់គ្រង ជាន់ខ្ពស់, លោក វណ្ណា ឡាញ់ អនុប្រធានផ្នែក អភិវឌ្ឍ, លោក ប៉ាហ៊ីម កៃ, លោក រស់ ទីល និងលោក សម្បត្តិ រិន។

ព័ត៌មានលម្អិតអំពីមូលនិធិភ្នំដងរែកមាននៅលើគេហទំព័រ http://dangrekfoundation.org/

អាស័យដ្ឋានៈ 64 MIDDLESEX ST., LOWELL, MA01852

អ៊ីម៉េលៈ phnom-dangrekfoundation@yahoo.com

**ទូរស័ព្ទៈ 978.729. 3149**

**ទូរសារៈ 978.891.8241**



# REMEDIUM PHARMACY

2 VINAL Square
N. Chelmsford, MA 01863

Phone: (978) 251-7070

## FREE Daily Home Delivery



**Blisterpack Packaging**

**Friendly Consultations**

**Compounded Medications**

**Easy Transfers**

បុគ្គលិកទាំងអស់របស់ឱសថស្ថានរីមីឌីមយើងខ្ញុំមានបទពិសោធន៍គ្រប់គ្រាន់ក្នុងការបំរើសេវាផ្តល់ឱសថជូនដល់សហគមន៍ខ្មែរ។ គេទាំងអស់គ្នាបានត្រៀមរួចជាស្រេចដើម្បីជួយ និង ត្រៀមបំរុងជានិច្ច ដើម្បីប្រើគ្រប់ជំនាញ និងការពិសោធន៍ក្នុងការបំរើលោកអ្នក។

ឱសថស្ថានរីមីឌីម ផ្តល់ជូនលោកអ្នកនូវៈ

**ជូនឱសថឲ្យដល់លំនៅស្ថានដោយឥតគិតថ្លៃ**
**ដាក់ឱសថក្នុងបន្ទះបែងចែកឱសថសំរាប់ប្រើតាមពេល**
**ការពិគ្រោះយោបល់យ៉ាងរាក់ទាក់ស្និទស្នាល**
**មានផ្តល់ជូនម្សៅថ្នាំលាយ**
**ភាពងាយស្រួលក្នុងការផ្ទេរចេញចូល**






**Cristina គ្រីស្ទីណាៈ**
គ្រីស្ទីណាមានការពិសោធន៍គ្រប់គ្រាន់នៅក្នុងកិច្ចការបំរើសហគមន៍ខ្មែរក្រុងឡូវែលអស់រយៈពេលជាង៣ឆ្នាំមកហើយ។អ្នកស្រីគឺជាឱសថការិនីដែលគ្រប់គ្រងឱសថស្ថាន រីមីឌីម នេះ ហើយគាត់ក៏អាចធ្វើការពិគ្រោះអំពីឱសថ ជូនលោកអ្នកដល់ផ្ទះផងដែរ។ ដោយសារការផ្តល់នូវសេវាកម្មផ្នែកឱសថនេះ បានច្បាស់លាស់ទើប អ្នកស្រីអាចបង្កើត បាននូវចំណងមិត្តភាពយ៉ាងល្អប្រពៃក្នុងសហគមន៍ខ្មែរក្នុងក្រុងឡូវែល ហើយអ្នកស្រីមានសេចក្តីរីករាយណាស់ដើម្បីរង់ចាំបំពេញនូវបំណងរបស់លោកអ្នកដែលត្រូវការឱសថ។



**Pahim លោកប៉ាហ៊ីមៈ**
គឺជាបុគ្គលម្នាក់ដែលមានការគោរពច្រើននៅក្នុងសហគមន៍ខ្មែរ គាត់ក៏ជាសមាជិកម្នាក់នៅក្នុងគណកម្មការវត្តត្រៃរតនារាម ហើយធ្លាប់មានការពិសោធន៍ជាច្រើនឆ្នាំក្នុងការជួយសហគមន៍ដែលត្រូវការព្យាបាលជម្ងឺ។ ក្នុងរយៈកាលកន្លងមក គាត់ធ្លាប់បានធ្វើការយ៉ាងច្រើនជួយគាំទ្រដល់អ្នកជម្ងឺនៅមជ្ឈមណ្ឌលសុខភាពសហគមន៍ក្រុងឡូវែលនិងមណ្ឌលសុខភាពពេទ្យមេត្តា ព្រមទាំងធ្លាប់បានចូលរួមចំណែកក្នុងការថែទាំដោយឱសថសំរាប់សហគមន៍ខ្មែរក្រុងឡូវែលអស់រយៈពេលជាង២ឆ្នាំផងដែរ។ ក្នុងនាមជសមាជិកម្នាក់នៃឱសថស្ថានរីមីឌីម គាត់នឹងបន្តធ្វើការបំរើឱ្យកាន់តែខ្លាំងខ្លាថែមទៀតដើម្បីបំពេញនូវតំរូវការក្នុងការផ្តល់ឱសថដល់លោកអ្នក។



**Dary ដារីៈ**
តែងបានយកចិត្តទុកដាក់ជាប់ជានិច្ចក្នុងសេវាកម្មផ្តល់ឱសថ ដើម្បីបំពេញតាមតំរូវការនៃសហគមន៍ខ្មែរក្រុងឡូវែលអស់រយៈជាង២ឆ្នាំមកហើយ ហើយតែងទទួលបាននូវការកោតសរសើរពីសំណាក់អតិថិជនដែលបានជួបប្រាស្រ័យជាមួយគាត់។ ក្នុងឋានៈជាអ្នកបច្ចេកទេសម្នាក់របស់ឱសថស្ថាន គាត់មានការយល់ដឹងយ៉ាងជ្រៅជ្រះអំពី តំរូវការ និងប៉ិនប្រសប់ក្នុងការផ្តល់សេវាជូនលោកអ្នកនិងចេះសំដែងនូវការគោរពយ៉ាងទន់ភ្លន់ចំពោះលោកអ្នកផងដែរ។



**Kelly ខែលលីៈ**
គឺជាឱសថការិនីយើងដែលអាចនិយាយភាសាខ្មែរហើយដែលយកចិត្តទុកដាក់ចេះជួយលោកអ្នក។ គាត់ជាឱសថការិនី ចេញពីមហាវិទ្យាល័យឱសថសាស្ត្ររដ្ឋម៉ាសាឈូសេត និង ពេញចិត្តធ្វើការបំរើសហគមន៍ខ្មែរដែលគាត់ក៏ជាសមាជិកម្នាក់នៃសហគមន៍នេះដែរ។



**Daniela ដានីញែលឡាៈ**
មានជំនាញច្បាស់លាស់ក្នុងការវេចខ្ចប់ឱសថដាក់ក្នុងបន្ទះពង្រាយថ្នាំសំរាប់ប្រើតាមពេល ហើយធ្លាប់ឆ្លងកាត់ការថែទាំអ្នកជម្ងឺខ្មែរដែលរស់នៅក្នុងក្រុងឡូវែលនេះអស់រយៈពេលជាង៣ឆ្នាំមកហើយ។ ប្រសិនបើលោកពេញចិត្តនឹងការប្រើថ្នាំដាក់ក្នុងបន្ទះបែបនេះ ដានីញែលឡាពេញចិត្តណាស់នឹងធ្វើកិច្ចការនេះជូនលោកអ្នក។



**Kassandraកាសាន់ដ្រាៈ**
គឺជាបុគ្គលិកដែលមានការពិសោធន៍ច្រើនក្នុងការធ្វើទំនាក់ទំនងជាមួយសហគមន៍ខ្មែរ និងស្បានិសសដែលរស់កក្នុងងក្រុងឡូឡូវែលលនេះ។
លោកអ្នកអាចនឹងពេញចិត្តអំពីភាពរាក់ទាក់រាល់ពេលនិយាយឆ្លើយឆ្លងតាមទូរស័ព្ទជាមួយនាង និងប៉ិនប្រសប់ក្នុងការរៀបចំឱសថជូនលោកអ្នកនៅរាល់ពេលដែលលោកអ្នកត្រូវការ។

# គណៈកម្មាធិការសាលារៀនទីក្រុងឡូវែល

**បកប្រែដោយៈ តារាយុទ្ធ**

ការសំរេចចិត្តរបស់គណៈកម្មាធិការសាលាទីក្រុងឡូវែលនឹងមានឥទ្ធិពលទៅដល់ការអប់រំរបស់សាលារដ្ឋយើងនាឆ្នាំខាងមុខនេះ។

តើគណៈកម្មធិការសាលាទីក្រុងឡូវែលមានមុខងារអ្វីខ្លះ?

**១-**អភិវឌ្ឍន៏គំរោងរដ្ឋបាលនឹងជួលនូវអ្នកគ្រប់គ្រង។

**២-**វវាយតម្លៃយ៉ាងម៉ដ្ឋចត់ទៅលើនយោបាយរបស់ខ្លួន។

**៣-**រៀបចំនូវគំរោងថវិការ ដើម្បីអនុម័តនូវនយោបាយរបស់ខ្លួន។

**៤-**ទំនាក់ទំនងជាមួយនឹងប្រជាជនអំពីតំរូវការនឹងគោលបំណងរបស់ពួកគេ។

**៥-**ការបង្កើតនូវការអប់រំដ៏ច្បាស់លាស់មួយ។

**នរណាខ្លះគឺជាគណៈកម្មធិការ?**

គណៈកម្មាធិការមានចៅហ្វាយក្រុងដែរ ធ្វើជាប្រធាននឹងសមាជិកប្រាំមួយនាក់ទៀតដែរ ត្រូវបានគេបោះឆ្នោតឱ្យជាប់រយៈពេល២ឆ្នាំ។

សមាជិកវិទ្យាល័យបច្ចេកវិទ្យាតំបន់ទីក្រុងឡូវែលដែលបានបំរើទីក្រុងឡូវែលទីក្រុងត្រាខាត់ (Dracut) ដុនស្ដេបបល់(Dunstable) ប៉េពរេ (Pepperell) នឹង ធីងប៊ូរ្វ (Tyngsboro) ត្រូវបានគេបោះឆ្នោតឱ្យជាប់ធ្វើជាគណៈកម្មធិការរយៈពេលពីរ បីរ ឬក៏បួនឆ្នាំ។

ថ្មី១នេះទីក្រុងឡូវែលមានសមាជិកចំនួន៤នាក់ នឹងត្រាខាត់ មានចំនួន២នាក់ ដុនស្ដេបបល់ នឹង ធីងប៊ូរ្វ មានម្នាក់២៕

**សមាជិកគណកម្មាធិការសាលារៀន ទើបជាប់ឆ្នោតសំរាប់អាណត្តិ២ឆ្នាំ**




# Lowell School Committee

The current Committee's decisions will influence the course of education in our public schools for years to come.

What does Lowell School Committee do?

**1.** Develops administrative plan and hires superintendent.

**2.** Evaluates effectiveness of its policies.

**3.** Adopts budget to carry out policies.

**4.** Communicates with Lowell citizens about needs and wishes.

**5.** Establishes educational objectives.

**Who is on the Committee?**

The Committee consists of the mayor, who serves as chair, and six at-large members who are elected to two-year terms.

Greater Lowell Technical HS, serving city of Lowell, and towns of Dracut, Dunstable, Pepperell, and Tyngsboro

Members are elected to serve terms of two, three, or four years.

Lowell currently has four members, Dracut has two, and Dunstable and Tyngsboro each have two.


**បន្ថយចំណាយថ្លៃភ្លើង និងហ្គាស**

ខែរងាមកដល់ ចំណាយថ្លៃភ្លើង និងហ្គាស និងឡើងថ្លៃគួរឱ្យបារម្ភ
-ចង់បញ្ចុះតម្លៃពី២០-៤០% សូមទូរស័ព្ទមក

**Pin Samkhon: 978-942-1641**
**Alex: 978-569-6034**



**សាលារៀន ហេឡេនីក អាមេរិកាំង**
HELLENIC AMERICAN ACADEMCY



PreK 3 to grade 8
បើកពីថ្នាក់ ត្រៀមកុមារ៣ឆ្នាំ រហូតដល់ថ្នាក់ទី៨ / សាលាដ៏មានឈ្មោះល្បី
នៅតំបន់ឡូវែល ឥឡូវបើកឱ្យចុះឈ្មោះថ្នាក់ត្រៀមកុមារ៣-៤ឆ្នាំ

**Academy Feature**

| | |
|---|---|
| • អាជ្ញាប័ណ្ណNEASC | NEASC Accreditation |
| • អាជ្ញាប័ណ្ណរបៀបរៀនសូត្រតឹងតែង | Rigorous Common Core Curriculum |
| • គ្រូបង្រៀនថ្នាក់មានសិស្សតិច | Low Student/Teacher Ratio |
| • កម្មវិធីរៀនភាសាទីពិរ | Second Language Programs |
| • កន្លែងក្មេងលេង មានសុវត្ថិភាព | Secure Playground |
| • មើលក្មេង មុន នឹង ក្រោយពេលចូលរៀន | Before/After School Daycare |
| • មានបង្កើតព្រឹត្តិការណ៍វប្បធម៌ | Cultural Events |

ដើម្បីបានព័ត៌មានបន្ថែមឬចង់ទៅមើលសាលា សូមទូរស័ព្ទ
**978-453-5422**





**Clemente Park Chiropractic**

Chetra A. Keo, D.C.

851 Middlesex Street. Lowell, MA 01851
**(978) 937-1492**

**Treatments**

| | |
|---|---|
| • Neck Pain | • ឈឺ-ក |
| • Back Pain | • ឈឺខ្នង |
| • Lower Back Pain | • ឈឺចង្កេះ-ខ្នង |
| • Automobile Injuries | • គ្រោះថ្នាក់រថយន្ត |
| • Personal Injuries | • រងរបួស |
| • Work Related Injuries | • របួសនៅកន្លែងធ្វើការ |

WE ARE EXPANDING!
យើងនឹងបើកកន្លែងថ្មីមួយទៀត!

New Location in Lynn Opening in October!
383 Chestnut St. Lynn, MA 01904

# មេធាវីថមាសស្ទីលីអាណូស

- ជួយធ្វើតាក់ដោយមិនបាច់មានលេខសូស្យាល់ (Filling Tax without Social Security)
- ជួយធ្វើគ្រីនកាត ១០ ឆ្នាំអោយបានបន្ទាប់ពីមានការលែងលះគ្នា (Divorced 10 year Green Card)
- ជួយធ្វើគ្រីនកាត ២ ឬ ១០ឆ្នាំ (Help with 2 or 10 year Green Card)
- ជួយអ្នកដែលនៅលើសកំណត់អោយបាននៅក្នុងប្រទេសបន្តទៀត (Help Overstay Bars)
- ជួយការពារកុំអោយគេបញ្ជូនទៅស្រុកវិញបន្ទាប់ពីបានប្រព្រឹត្តិខុសច្បាប់ (Criminal Deportation)
- ជួយរៀបចំឯកសារធានាឪពុកម្តាយកូននិងបងប្អូនមកអាមេរិច (Get Parents, Children and Sibling Here)
- ជួយរៀបចំឯកសារសំរាប់ធានាប្តីប្រពន្ធ ឬគូរដណ្តឹងមកអាមេរិច (Get Spouse or Fiancé Here)
- ជួយរៀបចំឯកសារសុំលែងលះប្តីប្រពន្ធ (Divorce, only in Massachusetts)
- ជួយការពារ និងធ្វើជាតំណាងក្នុងរឿងគ្រោះថ្នាក់ចរាចរណ៍ (Car Accident, only in Massachusetts)
- ជួយធ្វើការតវ៉ានៅចំពោះមុខក្រុមប្រឹក្សាសាលាឧទ្ធរណ៍ផ្នែកអន្តោប្រវេសន៍ (BIA Immigration Appeals)
- ជួយធ្វើឯកសារចូលសញ្ជាតិដល់សាម៉ីខ្លួន និងកូនៗរបស់លោកអ្នក (N-400 and N-600)
- ជួយធ្វើគ្រីនកាតថ្មីបន្ទាប់ពីត្រូវគេលួច ឬបាត់បង់ (I-90, Replacement Green Card)
- ជួយសុំកាតធ្វើការ (Work Card)
- ជួយធ្វើលិខិតធ្វើដំណើរចេញចូល (Re-entry Permit)

## Thomas Stylianos Law Offie

## 287 Appleton Street, Suit 205 Lowell, MA 01852

## Tel: 978-459-5000

**E-mail:** Tom@stylianoslaw.com

Attorneys' only licensed in Massachusetts

តមកពីទំព័រទី ០១

## ចូលឆ្នាំ២០១៦នៅអូឡិនដូ...

ដែលមានភ្ញៀវច្រើននឹងច្រកចូលឆែកសន្តិសុខមានប្រមាណ១០ច្រកប៉ុណ្ណោះបណ្តាលឱ្យមនុស្សរាប់ម៉ឺននាក់បន្តកន្ទុយវែង ហើយច្រើនខ្សែដោយមិនឿយហត់។ ចុងបញ្ចប់យើងក៏បានចូលទៅដល់ក្នុងបរិវេណដែលខ្ញុំហាក់ដូចជាខ្ញុំបានចូលក្នុងពិភពនៃក្តីស្រម័យមិនអាចជឿបានទេ ប្រសិនបើខ្ញុំមិនបានទៅដល់ទីនោះទេ។

គេនាំគ្នាទៅជិះរថភ្លើងម្យ៉ាង យុវជនអាយុច្រើនជាងខ្ញុំ ទើបអាចទៅជិះរថភ្លើងបើកវិលវល់ចុះឡើងយ៉ាងលឿននៅលើមេឃធ្វើឱ្យអ្នកជិះភិតភ័យស្រែកស្ទួនស្នោតែមិនមាននរណារបួសទេ គ្រាន់តែភ័យប៉ុណ្ណោះ... រីឯខ្ញុំក៏ឈរមើលសោះក៏ភ័យជំនួសគេដែរ។ ខ្ញុំទៅមើលអាងដាក់សត្វសមុទ្រមានសត្វខ្លះចម្លែកខ្លះ ខ្ញុំមិនដែលឃើញទាល់តែសោះតែសត្វឯទៀតធ្វើឱ្យខ្ញុំរីករាយ ដោយធ្លាប់ឃើញវានៅក្នុងសៀវភៅមើលពេលចូលកេងរបស់ខ្ញុំ ។

មានសត្វ"ភេនឹងដ៏វីទឹក"ចេះយល់ភាសាមនុស្សចេញមកលេងល្ខោនឱ្យសាធារណជនមើល គួរឱ្យចង់មើលណាស់ ក្រៅពីនេះនៅមានសត្វ "ដុលហ្វីន" សត្វកំប្រុក សូម្បីតែត្រីបាឡែន ក៏គេអាចនិយាយគ្នាយល់ ហើយបញ្ជាឱ្យធ្វើការបង្ហាញកីឡាបង្ហាញសាធារណជនបានដែរ។

នៅមានការសម្តែងរបាំ"រំអិលលើទឹកក"នៅពេលរាត្រីនៅលើឆាកដ៏ធំមួយនៅជាប់នឹងបឹងដែល

តទៅទំព័រទី ១១


រីករាយនៅ"ពិភពសមុទ្រ"អ័រឡិនដូ








MIDDLESEX
Community College
BEDFORD • LOWELL



Everyone teaches, everyone learns.

Middlesex offers 70+ degree & certificate programs, and hundreds of noncredit courses. Earn a degree, begin a bachelor's degree or upgrade your skills.

- A price you can afford
- Small-class environment
- Flexible schedule
- Online or on campus

Classes begin
JANUARY 25
REGISTER NOW!

STAY CONNECTED...

To learn more, call 1-800-818-3434 or visit www.middlesex.mass.edu

តមកទំព័រទី ០១

## ពិធីសម្ពោធគណក្រុមប្រឹក្សា...

សមាជិក៩រូប បានធ្វើសច្ចាប្រណិធាន ដោយសូត្រពាក្យសម្បតសម្រាប់តួនាទីខ្លួននៅសាលាក្រុង។ ជាមួយគ្នានោះក៏មានអ្នកស្បត់ម្នាក់ដែរ គឺ អេដវ៉ដ ខេណ្ណឺឌី ដែលបានក្លាយជាអភិបាលក្រុងថ្មី នឹងអភិបាលក្រុងរងម្នាក់ទៀតគឺ ដាញែល រូក។

អភិបាលក្រុង ខេណ្ណឺឌី បានថ្លែងទៅអ្នកមកចូលរួមដំបូងណែនាំឱ្យស្គាល់គ្រួសារលោករួចបន្តថា អភិវឌ្ឍន៏សេដ្ឋកិច្ច គឺជាការយកចិត្តទុកដាក់ជាអាទិភាពរបស់លោក ដូចជាចំណាយមានក្បួនប្រសើរ ហើយការយកពន្ធក៏សម្រេចទៅតាមសេចក្តីត្រូវការទៅថ្ងៃមុខ នៅពេលមានចំណាយនឹងគាំទ្រសេវាសាលាក្រុង។ អាទិភាពផ្សេងទៀតមានសន្តិសុខសាធារណៈបង្កើនគុណភាពសេវាសាលាក្រុងបង្កើនគុណភាពប្រព័ន្ធសិក្សាធិការបន្ថយពន្ធដារលើអចលនវត្ថុដែលកិច្ចការទាំងអស់នេះមិនអាចធ្វើទៅសម្រេចបានតែម្នាក់ឯងនោះទេ គឺជាកាងារក្រុមប្រឹក្សាក្រុងរួមគ្នា។

អភិបាលក្រុង ខេណ្ណឺឌី និយាយទៅក្រុមប្រឹក្សាក្រុងមុនថា បានធ្វើការរួមគ្នាបង្កើតជាអភិវឌ្ឍន៏ជូនដល់ឡូវែល តាំងពី២-៣ឆ្នាំមកហើយ ហើយដែលសំខាន់នោះ គឺការពិគ្រោះយោបល់ ខ្វែងគំនិតគ្នា នឹងធ្វើការទាំងអស់គ្នាដោយមិនបែកបាក់គ្នា។ អភិបាលក្រុង ខេណ្ណឺឌី



ក្រុមប្រឹក្សាធ្វើសច្ចាប្រណិធាន



លោក ដាញែល រូក ស្បថចូលកាន់តំណែងជាអនុប្រធាន

បាននិយាយអំពីការអំពាវនាវរបស់ក្រុមប្រឹក្សាក្រុងឱ្យប្រើទ្រឹស្តីពីក្រុង ឬសង្កាត់ ដើម្បីទៅរកធន់ធាន់ ពីកីរីតរដ្ឋ ឬពីសហព័ន្ធពីគំនិតថ្មីៗ នឹងរកដំណោះស្រាយសម្រាប់ការប្រកួតប្រជែងរបស់"តំបន់"។

តទៅទំព័រទី ២២

Continued from page 01

# City Council Inauguration...

the official notice of the election, resulting in a new city councilman, Jim Leary. The nine city councilors were sworn in by reciting the oath of this position in office. Also elected and sworn in were Lowell's new mayor,

Edward Kennedy and elected as the Vice Chairman was councilman Daniel Rourke.

Mayor Kennedy addressed attendees and introducing his family. Speaking to the crowd, Mayor Kennedy named economic development as a primary focus as it is the best method to expand the tax base and reducing the need for further tax increases when expanding or supporting municipal services. Other priorities mentioned were public safety, increasing quality of municipal services, improving the school systems, reducing real estate taxes; all

**Continued to Page 30**

# បង្ហាញផែនការសុខភាពរបស់ TUFTS នៅ VMart

**ដោយ : ខ្មែរផុសស.រ.អា.**

នៅពេលដែលសហគមន៏អាស៊ីមករស់យូរឆ្នាំនៅសហរដ្ឋអាមេរិកនេះ មនុស្សជាច្រើនមានកូឡេស្តេរល នឹងសម្ពាធឈាមបានយ៉ាងងាយស្រួលនឹងធ្វើតាមបាន...ដែលនេះជាផលចំណេញរបស់មនុស្សចាស់ជាច្រើនដែលខិតខំស្វែងរកម្នាក់១ដបដល់គ្រប់ភ្ញៀវដែលបានមកទទួលព័តិមានដោយនិយាយពីគុណភាពប្រេងរុក្ខជាតិនេះថា "ជាប្រេងដែលមិនកកនៅក្នុងសរសៃឈាមរក ដើម្បីទប់ស្កាត់កូឡេស្តេរល-លើសឈាម-នឹងឡើងទម្ងន់ ជាពិសេសសម្រាប់ធ្វើម្ហូបបួសដល់យើងផងដែរ។









សុខភាពមិនប្រក្រតីដោយសារធាតុអាកាសមិនដូចគ្នានឹងអ្វីដែលយើងមាទម្លាប់រស់នៅដោយសារម្ហូបចំណីក៏មិនដូចគ្នា ម្ល៉ោះហើយធ្វើឱ្យរូបរាងកាយធំធាត់ហួសកំណត់ថែមទាំងខ្លះទៀត ក៏មានជម្ងឺប្រចាំកាយដូចជាលើសសម្ពាតឈាម ឬក៏ឡើងជាតិខ្លាញ់ក្នុងសរសៃស្ទើរឱ្យមានការស្ទះឈាមរត់ជាដើម។






TUFTS ជាអង្គការថែទាំសុខភាពមនុស្សចាស់បានសហការជាមួយហាងលក់គ្រឿងឧបភោគបរិភោគ VMart នៅឡូវែលបញ្ចេញនូវកម្មវិធីមួយបង្ហាញជូនសាធារណជននៅថ្ងៃទី១៩ធ្នូមុននេះបង្កើតមុខម្ហូបដ៏មានផាសុខភាព អាចគ្រប់គ្រងទប់ស្កាត់ ការលើសឈាម ឬមានជាតិខ្លាញ់កកនៅក្នុងសរសៃឈាម ។ ជម្ងឺទាំងពីរនេះ បើមិនគ្រប់គ្រងវារាល់ថ្ងៃទេ អាចប៉ះពាល់គ្រោះថ្នាក់ដល់ជីវិតយ៉ាងឆាប់រហ័ស។ ថែមពីលើនេះ បុគ្គលិក TUFTS បានជូនដល់ភ្ញៀវនូវប្រេង"អូលីវ"ដបធំពេលប្រើវាធ្វើម្ហូបអាហារនឹងធ្វើឱ្យចុះទម្ងន់ទៀតផង"។

នៅពេលជាមួយគ្នានោះបុគ្គលិក VMart អតីតហាងបាត់ដំបងបានបង្ហាញនូវផលិតផល "ម្ហូបរុក្ខជាតិ" រាប់សិបមុខដែលមនុស្សចាស់តែងស្វែងសហការដ៏មានប្រយោជន៏ដល់សុខភាពនេះអាចបន្តអាយុចាស់ៗឱ្យបានវែងឆ្ងាយ ជាពិសេសផ្នែកម្ហូបចំណីអាហារដែលពួកគាត់"អាចព្យាបាលខ្លួនគាត់ដោយខ្លួនឯង"បាន ។ រីឯអ្នកលក់ម្ហូបចំណីវិញ ក៏គួរបន្ថែមគុណភាពលក់ម្ហូបចំណីឱ្យបានស្រស់ៗម្ហូបចំណីមិនលើសថ្ងៃកំណត់លក់កន្លែងលក់មានសោភណ្ឌភាពនឹងគ្មានក្លិនស្អុយឆ្អាបដែលបញ្ជាក់ពីគុណភាពទាប ធ្វើឱ្យខូចសុខភាពនៃម្ហូបចំណីទាំងនោះ ៕

**TUFTS Phone number: (617)335 4756**



# ការវិភាគ

របស់ព្រះតេជព្រះគុណបណ្ឌិត ហុក សាវណ្ណ

ថ្ងៃ៧មករា១៩៧៩ ជាថ្ងៃបែបណាក្នុងបំណងវៀតណាម

នៅឆ្នាំ១៩៧០ កងទ័ពវៀតណាមបានចូលមកប្រទេសកម្ពុជា តាមសេចក្តីអំពាវនាវរបស់សម្តេចនរោត្តមសីហនុដើម្បីវាយរបបលោកលន់ណុល។ ពេលនោះ ខ្មែរក្រហមជាសិស្សរបស់វៀតណាមដែលបានបង្ហាត់បង្រៀនយុទ្ធសាស្ត្រ ដែលបានសម្ភារៈចម្បាំងពីប្រទេសចិនកុម្មុយនិស្ត។ ដំបូងវៀតណាមបានគាំទ្រខ្មែរក្រហមយ៉ាងខ្លាំងក្លា។ នៅឆ្នាំ១៩៧៧ អាជ្ញាធរអង់គ្លេសបានស្រែកអំពាវនាវថា តាមដំណឹងពីអ្នកភៀសខ្មែរថា មានការសម្លាប់រង្គាលនៅកម្ពុជាដោយខ្មែរក្រហម ដូច្នេះ សូមអន្តរជាតិជួយធ្វើអន្តរាគមន៍។ ពេលនោះ សហភាពសូវៀតនិងវៀតណាមបានស្រែកប្រឆាំងថា នេះជាកិច្ចការផ្ទៃក្នុងរបស់ខ្មែរ មិនត្រូវបរទេសចូលជ្រៀតជ្រែកឡើយ។

ក្រោយមក វៀតណាមបានប្រឆាំងនឹងខ្មែរក្រហមវិញ ដោយខ្មែរក្រហមបានងាកទៅរកចិនយ៉ាងខ្លាំង ហើយយកខ្លួនជាសត្រូវដោយលើកយោធាទៅឈ្លានពានវៀតណាម ដែលធ្វើឲ្យពលរដ្ឋខ្លួនស្លាប់ជាច្រើន។ វៀតណាមក៏សម្រេចចិត្តវាយកំចាត់ខ្មែរក្រហមប៉ុលពតនៅថ្ងៃ៧មករា១៩៧៩ ឲ្យបានមុនអន្តរជាតិធ្វើអន្តរាគមន៍ ហើយតែងតាំងខ្មែរក្រហមប្រឆាំងប៉ុលពតដែលរត់ទៅប្រទេសខ្លួន គឺគណបក្សប្រជាជនកម្ពុជាសព្វថ្ងៃនេះ។

ដូចពោលមកនេះបញ្ជាក់ថា វៀតណាមគ្មានបំណងរំដោះពលរដ្ឋខ្មែរចេញពីការកាប់សម្លាប់របស់ខ្មែរក្រហមឡើយ បើខ្មែរក្រហមមិនយកខ្លួនជាសត្រូវ ទោះពលរដ្ឋខ្មែរត្រូវស្លាប់ប៉ុន្មាននាក់ ក៏វៀតណាមគ្មានរវល់ដែរ ថែមទាំងជួយការពារដូចពោលមកហើយ។ មួយទៀត បើវៀតណាមជួយរំដោះពលរដ្ឋខ្មែរដោយធម៌សប្បុរសពិតមែន បន្ទាប់ពីរំដោះហើយ វៀតណាមត្រូវប្រគល់សិទ្ធិឲ្យពលរដ្ឋខ្មែរចាត់ចែងវាសនាខ្លួនដោយខ្លួនឯង ក្រោមកិច្ចជួយឧបត្ថម្ភពីអង្គការសហប្រជាជាតិ។ ផ្ទុយទៅវិញ បន្ទាប់ពីប្រមូលភោគទ្រព្យខ្មែរដឹកទៅប្រទេសខ្លួន វៀតណាមនៅកាន់កាប់ប្រទេសកម្ពុជា តាមផែនការរបស់ហូជីមិញ ដែលយកប្រទេសកម្ពុជានិងលាវជាសហព័ន្ធកុម្មុយនិស្តឥណ្ឌូចិនដែលប្រទេសខ្លួនជាប្រធាន។ បានសម្លាប់និងចាប់ដាក់គុកនូវចលនាតស៊ូខ្មែរ ពិសេសបានបង្កើតក៥ជាដើម។ តាមកិច្ចព្រមព្រៀងសន្តិភាពថ្ងៃ២៣តុលា១៩៩១ ធ្វើឲ្យផែនការកាន់កាប់កម្ពុជាដូចនៅលាវត្រូវបរាជ័យ ប៉ុន្តែជំនាញការនៅតែបញ្ជាលើបក្សប្រជាជនគ្រប់ក្រសួងដោយមិនចេញមុខ៕

វត្តខ្មែរកាណាដា,ថ្ងៃ៩មករា២០១៦;www.hoksavann.org;savannhok@yahoo.com

តមកពីទំព័រទី ០៨

# រដ្ឋាភិបាលក្រុងឡូវែល...

គំរោងថវិការ រួមបញ្ចូលនូវការចំណាយទៅលើសាលា ប៉ូលីស fire នឹងសុវត្ថិភាពសាធារណៈក្នុងចំណោមរឿងដ៏ទៃទៀត ។

**៣–**ការបញ្ចេញមតិលើបញ្ហាតំបន់នឹងការគ្រប់គ្រងចរាចរណ៍ ។

ច្បាប់សំរាប់ចែកដីមានផលប៉ះពាល់ទៅដល់គុណភាពរបស់អ្នកជិតខាងរបស់យើង ។ បញ្ហាការគ្រប់គ្រងចរាចរណ៍ បានធ្វើអោយមានភាពងាយស្រួល ឬក៏កាន់តែពិបាកក្នុងការធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ ។

ពួកគេក៏មានផលប៉ះពាល់ដល់សុវត្ថិភាពចរាចរណ៍ដែរ ។

**៤–**ការបញ្ចេញមតិលើច្បាប់ ឬបទបញ្ជា

ក្រុមប្រឹក្សាក្រុងអាចអនុម័តនឹងផ្លាស់ប្តូរនូវច្បាប់ដែរប៉ះពាល់ជីវិតរស់នៅសព្វថ្ងៃរបស់ពួកយើង ។ នេះគឺជាបញ្ជីនៃតំបន់ច្បាប់ខ្លះដែរ គ្រប់គ្រងដោយក្រុមប្រឹក្សាក្រុងឡូវែល

**Adult establishment**

**ការផ្សាយពាណិជ្ជកម្ម**

ប្រព័ន្ធរំលឹ

ឡានពេទ្យ

សត្វ

កង់ ក្តារ នឹង សម្បែជើងស្គី

ការសាងសង់នៃអាគារ

Building / dangerous

អ្នកស្ម័ង់មតិ នឹង មេធាវី

Curfew

Electrical standard

**វិភាគទាន**

ការទប់ស្កាត់នូវអគ្គីសភ័យ

ការសរសេរឬគូរគំនូរដាក់តាមជញ្ជាំងសាធារណៈ

អ្នកដើរលក់តវ៉ាន់ នឹងអ្នកលក់តវ៉ាន់បន្តិចបន្តួច

សុខភាព នឹងអនាម័យ

ស្តង់ដារផ្ទះ

របស់ដែរគេបោះចោល នឹង secondhand dealer

អាជ្ញាប័ណ នឹងការអនុញ្ញាត

Noise

ចំណតរថយន្ត នឹងការកំសាន្ត

ម្ចាស់ហាងបញ្ចាំ

សន្តិភាព នឹង good order

ការថែរក្សានូវទ្រព្យសម្បត្តិ

ការបង្កើតនូវភេជ្ជៈ

ផ្លូវ នឹង ចិញ្ចើមផ្លូវ

អាងហែរទឹក

ឡានតាក់ស៊ី នឹងសំលៀកបំពាក់នាក់បំរើ

ដើមឈើ

យានយន្ត នឹង ចរាចរណ៍

សំរាម នឹង ការកែច្នៃឡើងវិញ

ប្រព័ន្ធទឹក នឹង ឡូរ

ដីស្ងួត

តំបន់

**៥–**គូសបញ្ជាក់សមាជិកក្រុមប្រឹក្សាភិបាលសំរាប់អង្គការសាធារណៈផ្សេងៗទៀត ។

អង្គការខ្លះក្នុងចំនោមអង្គការទាំងនេះ រួមបញ្ចូល បណ្ណាល័យ ក្រុមប្រឹក្សាខាងមនុស្សចាស់ គណៈកម្មការខាង ភាពអត់ឃ្លាន នឹងគ្មានទីជំរក គណៈកម្មការជួយជនអន្តោប្រវេសន៏ គណៈកម្មការជនពិការនឹងផ្សេងៗទៀត ៕






## តមកទំព័រទី ០៨ ចូលឆ្នាំ២០១៦នៅអូឡិនដូ...

មានដើម "គ្រីស្តស៊ឹស" ដុសពេញបញ្ចេញពន្លឺពណ៌ចម្រុះប្តូរពណ៌ប្លែកៗ រហូតដល់យប់ជ្រៅ មិនធ្វើឱ្យខ្ញុំងងុយគេងទេ ខ្ញុំអាចនៅរង់ចាំការបាញ់កាំជ្រួចទៅលើមេឃនៅចំពីលើបឹងចម្រុះពណ៌នោះ ដែលនៅជុំវិញបឹងដ៏ធំនោះ មានអ្នកមើលរាប់ពាន់នាក់ នៅរង់ចាំមើលរហូតដល់កណ្តាលអាធ្រាត ។

ពេលម៉ោង១២យប់មកដល់គេនាំគ្នារាប់លេខបញ្ច្រាស់ពី១០រហូតដល់សូន្យ ទើបសម្លេង "កាំជ្រួច" ក៏ផ្ទុះឡើងយ៉ាងខ្លាំងបញ្ចេញពន្លឺព្រោងព្រាតពេញផ្ទៃមេឃ ធ្វើឱ្យមេឃពេលនោះក្លាយជាកម្រងផ្កាដ៏អស្ចារ្យចងដៃជូនពរសាធារណជនដែលកំពុងឱ្យថើបជូនពរគ្នាទៅវិញទៅមកពុកម៉ែ នឹងខ្ញុំ ក៏ធ្វើដូចគ្នា ហើយសម្លេង ក៏ឮបំពងថា "ហាប់ពីនូយា! ហាពីនូយា!" មិនដាច់ រហូតដល់បាញ់កាំជ្រួចចប់... ថ្ងៃថ្មី... នាទីថ្មី នៃឆ្នាំ២០១៦ ក៏មកដល់នៅជុំវិញបឹងដ៏អស្ចារ្យ នាក្រុង "អូលិនដូ" ដែលមានមនុស្ស-សត្វនឹងទេព្តា នៅលាយគ្នាក្នុង "ស្ថានសួគ៌នៃស៊ីវិល" នៅពាសពេញទីនោះ គួរឱ្យស្រឡាញ់ជាទីបំផុត... ទីបំផុតអារម្មណ៍ងោកងុយក៏មកដល់... ខ្ញុំក៏លាពុកម៉ែនឹងទេព្តាទាំងអស់... ហាប់ពីនូយា! ហ្គុតណាយ!... ៕


សួស្តីឆ្នាំថ្មី!




មើលបាញ់កាំជ្រួចនៅម៉ោង១២យប់ចូលឆ្នាំថ្មី




វេទិកា
អាជីវកម្មខ្នាតតូច
សហគមន៍ខ្មែរ-អាមេរិក
ថ្ងៃ ពុធ ទី ២០ ខែ មករា
សហការរៀបចំឡើងដោយ

ស្តាប់មតិវាគ្មិនអំពី៖
ភាពជាអ្នកដឹកនាំ, បញ្ហាប្រឈម
និង ការចូលរួមរបស់សហគមន៍

ថ្ងៃបើកវេទិកា៖
ថ្ងៃ ពុធ ទី ២០ ខែ មករា
ម៉ោង៖
៦-៨ យប់
ទីកន្លែងបើកវេទិកា៖
សមាគមខ្មែរ
465 School St., Lowell, MA
** មានផ្តល់ភេសជ្ជៈ និង អាហារសម្រន់ៗ

សមាគមខ្មែរ និង EforAll ដោយមានការគាំទ្រពីសាលាក្រុងឡូវែលនឹងបើកវេទិកាដំបូងសម្រាប់ពលរដ្ឋខ្មែរ-អាមេរិក ស្តីពីអាជីវកម្មខ្នាតតូចៗ អ្នកជំនាញមកពីផ្នែកផ្សេងៗនឹង ចូលរួមចែករំលែកបទពិសោធន៍ល្អៗ និង ប្រវត្តិជោគជ័យរបស់ពួកគាត់ៗ វេទិកានេះ នឹងមានវគ្គសំណួរចម្លើយផងដែរៗ

វាគ្មិនសំខាន់ៗរួមមាន៖
ដារី ត្រាន់៖ នាយិកាប្រតិបត្តិ-ក្រុមរបាំអង្គរ
ផលរដ្ឋា យ៉ែម៖ ម្ចាស់- ក្រុមហ៊ុនអចលនទ្រព្យ Global Realty Network
សម្បត្តិ នាង៖ ម្ចាស់- ភោជនីយដ្ឋាន Simply Khmer
សុបិន ពិន៖ ម្ចាស់- សារព័ត៌មានខ្មែរប៉ុស្តិ៍
សូមកក់កន្លែងមុន តាមរយៈគេហទំព័រ៖ http://cmaapanel.bpt.me

Theodore Edson Parker Foundation

បើអ្នកចង់ជ្រាបព័ត៌មានបន្ថែម សូមទាក់ទង ណាប៉េត ម៉ូង 978-454-6200 x 1018



យើងខ្ញុំយកចិត្តទុកដាក់ដើម្បីឲ្យលោកអ្នកញញឹម។
លោកអ្នកទទួលបានសេវាកម្មទន្តពេទ្យដោយមិនបង់ប្រាក់!





លោកអ្នកទទួលបានអត្ថប្រយោជន៍ទាំងអស់របស់លោកអ្នកនៅក្នុងកម្មវិធីស្តង់ដារ MassHealth និងកម្មវិធី Medicare រួមទាំងសេវាកម្មជាច្រើនទៀត។

- លោកអ្នកទទួលបានសេវាកម្មទន្តពេទ្យ ដោយមិនបង់ប្រាក់ ដែលរួមមាន៖ *
  - ពិគ្រោះយោបល់នៅការិយាល័យ និងសម្អាតធ្មេញ
  - ដាក់ក្រាសធ្មេញទាំងមូលនិងដោយផ្នែក
  - ប៉ះធ្មេញ
  - ដាំធ្មេញ
- ចំណាយបដិភាគ $0 សម្រាប់គ្រប់សេវាកម្ម
- ប័ណ្ណ លោកអ្នកមានសុខភាពល្អ សម្រាប់ទិញទំនិញពាក់ព័ន្ធនឹងសុខភាពដែលមិនមានវេជ្ជបញ្ជា (រហូតដល់ $140ក្នុងមួយឆ្នាំ / $35 ក្នុងមួយត្រីមាស) *
- សេវាកម្មដឹកសមាជិកទៅកាន់និងមកពីកន្លែងណាត់ជួប *
- អាចហៅទូរស័ព្ទទៅកាន់សមាជិកក្រុមការងារនៃគម្រោង SWH បាន 24/7

SWH
SENIOR WHOLE HEALTH®
Simple. Secure. Independent.

សម្រាប់ព័ត៌មានបន្ថែម សូមទូរស័ព្ទទៅ:
1-888-566-3526 (ខ្សែទូរស័ព្ទឥតគិតថ្លៃ) TTY/TDD:711
www.seniorwholehealth.com/SNP
យើងខ្ញុំបើកដំណើរការចាប់ពីម៉ោង 8 ព្រឹកដល់ម៉ោង 8 យប់ ប្រាំពីរ (7) ថ្ងៃក្នុងមួយសប្តាហ៍។

ប្រសិនបើលោកអ្នកមានសេវាកម្មធានារ៉ាប់រងក្នុងកម្មវិធីស្តង់ដារ MassHealth ក៏ប៉ុន្តែមិនមានសេវាកម្មធានារ៉ាប់រងក្នុងកម្មវិធី Medicare ផ្នែក A និង/ឬក៏ផ្នែក B លោកអ្នកប្រហែលជា អាចចុះឈ្មោះនៅក្នុងកម្មវិធីជម្រើសថែទាំសុខភាពមនុស្សចាស់ MassHealth Senior Care Options (SCO) របស់យើងខ្ញុំបាន។
លោកអ្នកដែលឆ្លើយតបទៅនឹងលក្ខខណ្ឌខាងលើអាចចុះឈ្មោះបានគ្រប់ពេលវេលារៀងរាល់ឆ្នាំ។

* លក្ខខណ្ឌកំណត់អាចត្រូវបានអនុវត្ត

គម្រោងសុខភាពទាំងមូលរបស់មនុស្សចាស់ គឺជាគម្រោងថែទាំសុខភាព HMO SNP ដែលមានការសម្របសម្រួល និងកិច្ចសន្យាផ្តល់- ទទួលសេវាកម្មនៃកម្មវិធី Medicare និងកិច្ចសន្យាជាមួយ Commonwealth of Massachusetts/កម្មវិធី EOHHS MassHealth។ ការចុះឈ្មោះធ្វើឡើងដោយស្ម័គ្រចិត្ត និងអាស្រ័យទៅលើការបន្តកិច្ចសន្យាប្រចាំឆ្នាំ។ ព័ត៌មានអំពីអត្ថប្រយោជន៍នៅក្នុងឯកសារនេះ គឺជាសេចក្តីសង្ខេបមួយ មិនមែនជាសេចក្តីពិពណ៌នាលម្អិតអំពីអត្ថប្រយោជន៍ទេ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងការិយាល័យគម្រោង។ លក្ខខណ្ឌកំណត់ ប្រាក់បដិភាគ ឬក៏លក្ខខណ្ឌកម្រិតផ្សេងៗទៀតអាចត្រូវបានអនុវត្ត។អត្ថប្រយោជន៍ រូបមន្ត បណ្តាញអ្នកផ្តល់សេវាកម្ម និងបណ្តាញឱសថស្ថាន អាចត្រូវបានផ្លាស់ប្តូរនៅថ្ងៃទី 1 ខែមករា នៃឆ្នាំនីមួយៗ។ លោកអ្នកត្រូវតែបន្តបង់បុព្វលាភផ្នែក B របស់លោកអ្នក ប្រសិនបើបុព្វលាភនោះមិនកំពុងត្រូវបានបង់ដោយភាគីណាមួយផ្សេងទៀតនៅឡើយទេ។ គម្រោងនេះត្រូវបានបង្កើតឡើងសម្រាប់មនុស្សដែលមានអាយុចាប់ពី 65 ឆ្នាំឡើងទៅ ដែលមានជំនួយវេជ្ជសាស្ត្រដែលទទួលបានទាំងពីរដ្ឋ និងកម្មវិធី Medicare។ H2224_2015_104kh Accepted 12/7/2014

# ១២យ៉ាងជួយរក្សានូវទឹកប្រាក់ដែលអ្នកឈ្នះ

**រៀបរាងដោយ តារាយុទ្ធ ហង្ស**

កាលពីថ្ងៃសៅរ៍ ទី១៣ ខែមករា ឆ្នាំ២០១៦ មន្ត្រីផ្នែកឆ្នោតបានរកឃើញថា មានមនុស្ស៣នាក់ដែលឈ្នះនូវរង្វាន់ធំនេះ នៅរដ្ឋ៣ខុសៗគ្នា ។ អ្នកទាំង៣នឹងចែកចំនួនប្រាក់១៥០០លាននេះស្មើៗគ្នា បន្ទាប់ពីកាត់ពន្ធជូនរដ្ឋប្រមាណជា៤០% ម្នាក់ ។

នេះក៏ជាទឹកប្រាក់រង្វាន់ដ៏លើសលុបបំផុតចាប់តាំងពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៣ នៅពេលដែរអ្នកទទួលរង្វាន់នៅឯសោតខារ៉ូលីនា (South Carolina) បានឈ្នះនូវរង្វាន់ចំនួន៣៩៩.៤លាន




ដុល្លារដែរ ជារង្វាន់ជាប់លេខ៦ធំបំផុតក្នុងប្រវត្តិសាស្ត្រផៅវើរប៉ល ។ ប៉ុន្តែឧទាហរណ៍បើអ្នកស្រមៃមើលថា បើសិនជាអ្នកឈ្នះនូវរង្វាន់បែបនេះ តើអ្នកនឹងគួរធ្វើដូចម្តេច ដើម្បីកុំអោយទឹកប្រាក់ដ៏ច្រើនបែបនេះបាត់បង់ទៅវិញ? ចំលើយមាន ១២វិធីដែរ ប្រហែលជាអាចជួយអ្នកឱ្យថែរក្សា




ទឹកប្រាក់ទាំងនេះបាន

**១-**កុំភ្លេចចុះហត្ថលេខា នៅលើសំបុត្រឆ្នោត រឺក៏កុំភ្លេចរាយការណ៍ទៅកាន់រដ្ឋរបស់អ្នក

ឧទាហរណ៍ បើសិនជាអ្នកស្រាប់តែជ្រុះបាត់នូវសន្លឹកឆ្នោតរបស់អ្នកតើអ្នកគួរធ្វើយ៉ាងណា នៅពេលគ្មានអ្វីសំគាល់ថា សន្លឹកឆ្នោតនោះគឺជារបស់អ្នកនោះ ។

**២-**កុំប្រាប់អ្នករាល់គ្នាអោយដឹង

ឧទាហរណ៍ ដូចដែរអ្នកដឹងហើយថា បើសិនជាមនុស្សម្នាក់ដឹងថាអ្នកមានប្រាក់រាប់លានដុល្លារនៅក្នុងខ្លួន តើគេនឹងធ្វើដូចម្តេច? អ្នកប្រកត់ជាមានឱ្យកាសច្រើនក្នុងការជប់គ្រោះថ្នាក់ ដូចជា ការចាប់ចំរិត រឺរងនូវការប្រព្រឹត្តអំពើអាក្រក់ផ្សេងៗចំពោះអ្នក ។

**៣.** កុំសំរេចចិត្តភ្លាមៗទទួលនូវប្រាក់សុទ្ធសរុបជាសជាងប្រាក់បំណាច់ឆ្នាំ

ពីព្រោះ អ្នកសំរេចចិត្តទទួលប្រាក់សុទ្ធសរុបប្រហែលជាជិត៧០%ធ្លាក់ខ្លួនក្រ ។ ដូច្នេះមុននឹងសំរេចចិត្តយកនូវប្រាក់សុទ្ធសរុប រឺក៏ប្រាក់បំណាច់ឆ្នាំ អ្នកគួរតែពិគ្រោះយោបល់ជាមួយនឹងអ្នកជំនាញផ្នែកពន្ធ រឺក៏អ្នកអោយយោបល់ផ្នែកវិនិយោគទុនសិន ។

**៤.** កុំជំពាក់នូវបំណុល

ពីព្រោះការជំពាក់នូវបំណុលអាចធ្វើអោយអ្នកមានបញ្ហានាពេលអនាគត ។ ឧទាហរណ៍ អ្នកឈ្នះឆ្នោតម្នាក់នៅឯ កាលីហ្វញ៉ាត្រូវបានគេរឹបអូសទ្រព្យសម្បត្តិដោយសារជំពាក់បំណុលអចលនទ្រព្យ ។

**៥.**កុំព្យាយាមចំណាយ រឺក៏ចាយវាយដូចជាអភិជន

ពីព្រោះការចំណាយបែបនេះអាចធ្វើអោយអ្នកមានទំលាប់អាក្រក់ ។ ឧទាហរណ៍ ប្រសិនជាអ្នកចាប់ផ្តើមលេងល្បែង អ្នកនឹងមានអារម្មណ៍ថាអ្នកនឹងមិនសប្បាយចិត្តទេរហូតទាល់តែអ្នកបានចាញ់នូវលុយរាប់ពាន់ដុល្លារ ។

**៦.**កុំព្យាយាមទិញនូវវត្ថុគ្រប់យ៉ាងសំរាប់អ្នករាល់គ្នា រឺសូម្បីតែខ្លួនរបស់អ្នក ពីព្រោះការធ្វើបែបនេះអាចធ្វើឱ្យមិត្តភ័ក្តិ គ្រួសារ របស់រំពឹងទៅលើអ្នកជារៀងរហូត ។

**៧.** រៀនគ្រប់គ្រងនៅការចំណាយ

ពីព្រោះអ្នកខ្លះនៅពេលដែរមានលុយច្រើនគេនឹងចាប់ផ្តើមចំណាយ នឹងទិញរបស់ថ្លៃៗដោយមិនខ្វល់គំរោងថវិការអ្វីទាំងអស់ នេះជាហេតុផលដែរអាចអោយអ្នកជួបនឹងវិបត្តិសេដ្ឋកិច្ច

**៨.**កុំព្យាយាមធ្វើជាធានាគារអោយគេខ្ចីប្រាក់

មិនថាអ្នកមាន រឺអ្នកក្រពេលខ្លះអ្នកតែងតែត្រូវការលុយដើម្បីបង្វិលនូវពេលដែរ ជួបនឹងបញ្ហាអ្វីមួយ

**៩.**កុំបរិច្ចាគប្រាក់របស់ខ្លួនទាំងអស់ ចូលមូលនិធិសប្បុរសធម៌

ស្រមៃមើលថា ថ្ងៃណាមួយនៅពេលដែរគ្រួសាររបស់ជួបបញ្ហាផ្នែកសេដ្ឋកិច្ច តើអ្នកនឹងគួរធ្វើដូចម្តេច?

**១០.** កុំព្យាយាមចំណាយដូចទៅនឹងតារា រឺក៏អត្តពលិកល្បីៗ

ការទិញនូវរបស់ឆើតឆាយគឺពិតជាធ្វើអោយអ្នកមានកិត្តិយសណាស់ ប៉ុន្តែអ្នកត្រូវដឹងថា ការធ្វើដំរាប់តាមអត្តពលិក រឺក៏តារាល្បីអាចធ្វើអោយអ្នកជួបនឹងវិបត្តិសេដ្ឋកិច្ចបាន ពីព្រោះចំណូលនឹងចំណាយរបស់ពួកគេខុសពីអ្នក ។

**១១.** កុំគិតថាអ្នកអាល្មើសនឹងច្បាប់បាន

នៅពេលដែរអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ អ្នកប្រកត់ជាគិតថាអ្នកអាចជួលនូវមេធាវីពូកែៗដើម្បីការពារអ្នក ប៉ុន្តែកុំភ្លេចថាច្បាប់មិនគិតថាអ្នកមាន រឺក៏ក្រទេ យុត្តិធម៌តែងតែមានជានិច្ច ។

**១២ .**ព្យាយាមរកនូវអ្នកជំនាញផ្នែកហិរញ្ញវត្ថុដើម្បីប្រឹក្សាយោបល់ជាមួយអ្នកក្នុងការ ការពារទ្រព្យសម្បត្តិរបស់អ្នកនាពេលអនាគត ។

ឧទាហរណ៍ តើអ្នកដឹងពីរបៀបដើម្បីការពារទ្រព្យសម្បត្តិរបស់អ្នកប្រឆាំងនឹងការគំរាមកំហែងទាំងអស់និងដឹងច្បាស់អំពីរបៀបដើម្បីការពារអចលនទ្រព្យរបស់អ្នកក្នុងករណីដែលអ្នកស្លាប់ដែរឬទេ?

# គណកម្មាធិការនាយកក្រុងខ្មែរឡូវែលបានត្រូវផ្លាស់ប្តូរ

## New Board Members of Cambodia Town

**ខ្មែរផុស ស.រ.អា.**

Lowell: បន្ទាប់ពិការលាឈប់របស់លោក តុលាយុទ្ធ អ៊ុក ពីតំណែងអនុប្រធាននឹងលោក ផលរដ្ឋា យ៉ែម ជាសមាជិក លោកស្រីប្រធានគណកម្មាធិកានាយកក្រុងខ្មែរឡូវែលថ្មី អាណាបែល សាធុកា ផល្លី បានបង្ហាញបញ្ជីរាយនាមរបស់គណកម្មាធិការស្រឡាងមួយដែលទទួលការតែងតាំងកាលពីថ្ងៃ៩មករា២០១៦ មានឈ្មោះដូចតទៅ:

**១-**អាណាបែល សាធុកា ផល្លី ប្រធាន
**២-**ទូច វ៉ាន អនុប្រធាន
**៣-**សាធ្យា ថាច់ លេខាធិកា
**៤-**ពិសាល ទូច ហិរញ្ញិក
**៥-**សុខមាស ជា ហិរញ្ញិក-ទំនាក់ទំនងរដ្ឋាភិបាល
**៦-**សុភក្ត្រា ណារា អ្នកកត់ហេតុ
**៧-**រដ្ឋ ម៉ម អ្នកឯកទេសពតិមាន



អាណា បែល សាធុកា ផល្លី ប្រធានក្រុងខ្មែរឡូវែលថ្លែងការណ៍នៅសាលាក្រុង

**៨-**ចម្បា ប៉ាង ទំនាក់ទំនងពាណិជ្ជកម្ម-រៀបចំពិធីការ
**៩-**ផាមារ៉ូ អ៊ុង ទំនាក់ទំនងសាធារណ
**១០-**ឡាក់ សុខ ទំនាក់ទំនងសហគមន៏-មេដឹកនាំប្រមូលធនធាន
**១១-**រដ្ឋា ខៃ ជំនួយការទូទៅ
**១២-**នឿន ចាន់ ជំនួយការទូទៅ

"ឈ្មោះនឹងតួនាទីបកប្រែក្រៅផ្លូវការ"

ការរៀបគម្រោងគ្រប់គ្រងសាជាថ្មីនេះ លោកស្រី ផល្លី និយាយថា ធ្វើឡើងបន្ទាប់ពី តុលាយុទ្ធ បានលាលែងដោយមានអត្ថាធិប្បាយសម្តែងការមិនពេញចិត្តតាមកញ្ចក់ទូរទស្សន៏ថា" មិនអាចធ្វើការជាមួយគ្នានឹងប្រធានថ្មីកើតទេ" នឹងម្យ៉ាងទៀតថា "មិនភាពមិនប្រក្រតីនៅក្នុងការចាយវាយ"។ លោកស្រីផល្លីបានផ្តល់ចម្លើយតបវិញថា "ប្រាកដជាមិនអាចធ្វើការជាមួយគ្នាកើតទេបើតុលាយុទ្ធអសកម្មយ៉ាងនេះ" ចម្លើយចំពោះការចោទប្រកាន់ទី២ថា "នៅក្នុងហិបក្រុងខ្មែរគ្មានលុយទេ ចំណាយជាច្រើនចេញពីហោប៉ាវផ្ទាល់របស់ខ្ញុំ"។ លោកស្រី ផល្លី នឹងអនុប្រធាន ទូច វ៉ាន បានប្រាប់យើងពីគោលបំណងធំ របស់គណកម្មការក្រុងខ្មែរ គឺធ្វើឱ្យចេញស្លាដៃដំបូងរបស់ខ្លួនដាក់រូបព្រហ្មបាយ័នឱ្យបានចេញជារូបរាងនៅពីមុខក្រុងខ្មែរ នៅខែមិនាខាមុខឱ្យបាន ហើយនៅលើសំនួរថា"ហេតុអ្វីក៏មិនទទួលអំណោយពីរដ្ឋាភិបាលខ្មែរ?" អ្នកស្រីឆ្លើយថា "ខ្មែរនៅឡូវែលគេចង់បានរូបនោះជាស្នាដៃរបស់គេ ហេតុនេះហើយបានជាយើងធ្វើការឱ្យស្របតាមបំណងនេះ" អ្នកស្រីបន្ថែមថា "យើងនឹងធ្វើអ្វីគ្រប់យ៉ាងដើម្បីឱ្យមានតម្លាភាព ហើយទទួលបាននូវការទុកចិត្តពីបងប្អូនខ្មែរយើង"។

ចំណែកលោក ផលរដ្ឋា យ៉ែម បានលាឈប់ដោយសារគាត់រវល់ឈរឈ្មោះបោះឆ្នោត ៕



ចំការ"ស្វីតមេសិល"បានផលល្អ



សូបិន និងឪពុក ថាច់ យីប ពិគ្រោះគ្នាជាមួយ រី ឆឹត

# កសិករខ្មែរនៅរដ្ឋ"ផ្លរីដា"

**ដោយៈ ពិន សំខុន**

រដ្ឋ"ផ្លរីដា"ស្ថិតនៅចុងខាងត្បូងបង្អស់ នាផ្នែកខាងកើតនៃសហរដ្ឋអាមេរិក មិនត្រឹមតែល្បីល្បាញពេញក្នុងពិភពលោកដោយសារតែតំបន់ទេសចរ ដោយសារតំបន់នៃអ្នកមាននោះទេ តែក៏ជាតំបន់ដែលមានសីតុណ្ហភាពក្តៅ គ្មានរងាររហូតដល់ធ្លាក់ព្រិល ដូចនៅតំបន់ឯទៀតៗ នៃសហរដ្ឋអាមេរិកនោះឡើយ ។ ខ្ញុំនឹងគ្រួសារបានចេញដំណើរទៅកាន់តំបន់ដែលមានកំដៅដូចស្រុកយើង ជាថ្មីម្តងទៀតបន្ទាប់ពីឆ្នាំមុននៅពេលដែលឡូវែលផ្តើមធ្លាក់ព្រិលនាចុងឆ្នាំ២០១៥នេះ។ បុព្វហេតុម្យ៉ាងទៀត គឺ សូបិន បានរកទៅជួបឪពុករបស់ខ្លួនផងគាត់ឈ្មោះ ថាច់ យីប ដែលបានចេញមកពីឡូវែល ហើយចង់រស់នៅជាកសិករវិញ ដែលជាជំនាញអ្នកស្រុក "កម្ពុជាក្រោម" យើងដែល កាលពី៦ខែមុន គាត់ក៏បានគេចចេញពីឡូវែល ដោយសារបុព្វហេតុកំដៅនេះ១ ហើយម្យ៉ាងទៀត គាត់បានជួបឱកាសដែលអាចឱ្យគាត់ត្រឡប់ក្លាយទៅជាកសិករវិញបាន ជាមួយនឹងមិត្តភ័ក្រ្ត២នាក់ទៀត ឈ្មោះ រីកឆឹត នឹង វ៉ែន តែវ៉ែនថ្ងៃនោះ មិនបាននៅទីនោះទេ រវល់មក"ហ្វីឡាដែលហ្វៀ" ។ អ្នកទាំងបីបានទៅជួលដីចំការបានមួយដុំម្នាក់ ក្នុងទំហំ២អេគឺកន្លះម្នាក់ដីនៅជាប់ៗគ្នា នាតំបន់"ឥណ្ឌៀនថោន Indiantown" ក្បែក្រុង "ម៉ាយ៉ាម IMiami" ដ៏ល្បីល្បាញ ដោយទេសចរពិភពលោកមកលេង"ស្ថានសួគ៌លោកីយ"មិនចេះចប់។ ផ្ទុយនឹងទេសចរដែលគេមកកំសាន្តនឹងសម្រាកកាយអតីតកសិករយើងបានមករស់នៅលើដីចម្ងាយប្រមាណជា២ម៉ោង ពីទីក្រុងទេសចរនោះមកកាប់ឆ្ការដីព្រៃនាម មានផ្ទះខ្ទមមួយ ជាជម្រកដែលត្រូវជួសជុលសម្រាប់នៅចាំចំការ ក្នុងតម្លៃឈ្នួលដ៏យ៉ាងថោក។

នៅទីនោះ យើងបានដឹងថា កសិករខ្មែរមួយចំនួនមានដីធ្វើចំការដល់រយអេ គឺធ្វើដំណាំប្រកបដោយជោគជ័យ ខ្លះក៏បានក្លាយជា"មីល្យោណែ"ឬអ្នកមានលុយរាប់លាន ក្នុងរយៈពេលយ៉ាងខ្លី រួចទៅហើយ តើគេធ្វើដូចម្តេច ទើបបានក្លាយជាអ្នកមានចេញពីភាពក្រីក្របាន នៅពេលជួបពួកគាត់ភ្លាម ខ្ញុំឧទ្ទានថា "អស់សាច់ទៅហើយ តើវាទៅណាអស់?" គឺមិនមែនជាអ្នកក្រ"អស់សាច់"ទេ តែសាច់ខ្លាញ់ដែលមានពីមុនមក បានស្រកចេញអស់នៅសល់តែរូបរាងស្គាំងស្គមធូរខោធូរអាវ មើលស្ទើរមិនស្គាល់។ និយាយគ្នាមួយសន្ទុះ ខ្ញុំមានអារម្មណ៍ថា ពួកគាត់ស្គមតែមានកម្លាំង នឹងសុខភាពប្រសើរជាងមុន លោក រីកឆឹត បានបន្ថែមថា ខ្ញុំបានគេចផុតពីកង្វល់នៃដំបន់ឡូវែល យើង ដែលមានបញ្ហាមិនចេះចប់ មកគិតតែពីកិច្ចការចំការ ដាំដំណាំ បណ្តុះពូជស្រោចទឹក ដាក់ជី បោះបង្គោល ជំរះស្មៅ... ធ្វើឱ្យខ្លួនខ្ញុំ រលាយកង្វល់បាត់អស់ ទម្ងន់ក៏ស្រក សំពាតឈាមក៏ចុះ... ខ្ញុំមានសេចក្តីត្រេកអរជំនួសពួកគាត់ ដោយឃើញអ្នកទាំងនោះ បានរកឃើញនូវមុខរបរ ដែលខ្លួនចូលចិត្ត រស់នៅទីកន្លែងដែលត្រូវនឹងសុខភាពបន្ថែមពីនោះ គឺកាត់មានសេចក្តីសង្ឃឹមថានឹងធ្វើការបាន"ចំណេះថ្មី"ជាកសិករសម័យព្រមទាំងជោគជ័យជាមួយនឹងកសិករឯទៀតដែលកំពុងតែរស់ធូធារនៅក្បែគ្នា ។ នេះប្រាកដជាគំរូនៃ"ស្ថានសួគ៌ថ្មី"នៃកសិករខ្មែរ ដែលបានរៀនសូត្រខ្លះហើយមករស់នៅជាកសិករសាជាថ្មីនៅសហរដ្ឋអាមេរិកនេះ។ ប្តូរជីវភាពនៅ"ផ្លរីដា"ជាកសិករ ហាក់មិនពិបាកដូចជីវភាពជាកម្មករ ឬនិយោជិក នៅតំបន់ឯទៀតៗនោះទេ ហើយក៏មិនឃឹតពេលសម្រាប់ប្តូរជីវភាពក៏ទេដែរ។






ថ្នាលបណ្តុះគ្រាប់ពូជ

សូបិន នឹងខ្ញុំ បានទៅជួបនឹងកសិករខ្មែរម្នាក់ទៀត ឈ្មោះ សម ផេន ដែលមានចំការនៅមិនឆ្ងាយប៉ុន្មានពីចំការឪពុកគេ ។ ផេន ធ្វើចំការចំនួន៥ឆ្នាំមកហើយ ជាម្ចាស់នៃដី១00អេគឺ ហើយមានដំណាំផលិតនៅលើដីចំនួន៦0អេគឺ ដែលដំណាំធំរបស់គេ គឺធ្វើតែ១មុខគឺ"ស្វីតបេស៊ីត Sweet basil" នៅលើដី៤0អេគឺ ដែល ផេន ថៃយ៉ាងប្រយ័ត្នប្រយែងដូចកូនខ្ចីដោយមិនឱ្យនរណាចូលទៅដល់រងដំណាំដោយគ្មានអនុញ្ញាត្តិឡើយ។ ផេន ប្រើកម្លាំងពលកម្ម១៥នាក់ សម្រាប់កាត់លក់៣ថ្ងៃម្តង ដោយសារដំណាំដាំ តាមរបៀបទំនើបស្រោចទឹកជាស្វ័យប្រវត្តិ មានដំបូលគ្របការពារត្រជាក់ដាក់ជីឱ្យត្រូវការពារ កុំឱ្យមានសត្វស៊ី ផេង អាចកាត់លក់គ្រប់រដូវបានទៅឱ្យអតិថិជនតែម្នាក់ដែលជាអ្នកលក់ដុំ។ ផេន នៅមានដាំដំណាំបន្ទាប់បន្សំទៀត ជាដំណាំអាស៊ី ដាំនៅលើដី២0អេគឺទៀត ហើយបើកឡានធំដឹកទំនិញយកទៅលក់ដោយខ្លួនឯង នៅ"ហូមស្តេដ Homestead" ដែលស្ថិតនៅ២-៣ម៉ោងពីទីនោះ ។ ផេង បានបន្ថែមថា កាលពីឆ្នាំដំបូងខ្ញុំបានផ្តើមធ្វើដំណាំ **តទៅទំព័រទី២៨**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# ក្នុងសន្និបាតប្រចាំឆ្នាំរបស់ខ្លួន គណបក្សប្រជាជនកម្ពុជា លើកសរសើរខ្លួនឯងខ្ពស់ដល់កំពូល

**ដោយអូន ភាព** | **January 11.2016**

ខណៈសមាជិកជាន់ខ្ពស់របស់គណបក្សប្រជាជនកម្ពុជាកំពុងកាន់អំណាចជួបជុំគ្នាក្នុងរាជធានីភ្នំពេញនៅចុងសប្តាហ៍នេះ ដើម្បីចូលរួមសន្និបាតប្រចាំឆ្នាំរបស់ខ្លួន? គណបក្សនេះបានធ្វើការវាយតម្លៃខ្ពស់និងសរសើរខ្លួនឯងយ៉ាងច្រើន ហើយស្ទើរតែមិនបានគូសបញ្ជាក់ពីចំណុចត្រូវកែលម្អ នេះបើយោងតាមរបាយការណ៍មួយកម្រាស់៤៩ទំព័រដែលត្រូវបានចែកជូនគណៈប្រតិភូក្នុងសន្និបាតដែលមានរយៈពេលពីរថ្ងៃនេះ។

របាយការណ៍នេះលើកសរសើរចំពោះកំណើនសេដ្ឋកិច្ចឆាប់រហ័សរបស់ប្រទេស និងការអនុម័តច្បាប់ថ្មីដោយគ្រាន់តែលើកឡើងត្រួសៗប៉ុណ្ណោះជុំវិញបញ្ហានានាដូចជា អំពើពុករលួយ និងកង្វះតម្លាភាពជាដើមក្រៅពីគូសបញ្ជាក់អំពីសារៈសំខាន់ "ស្លាប់រស់" នៃការបន្តធ្វើកំណែទម្រង់។

របាយការណ៍ច្បាប់ចម្លងដែលបានបែកធ្លាយនេះ ត្រូវបានលោក សម រង្ស៊ី ប្រធានគណបក្សប្រឆាំងផ្ញើអ៊ីម៉ែលទៅកាន់សមាជិកប្រព័ន្ធផ្សព្វផ្សាយកាលពីថ្ងៃសៅរ៍។ ភាពត្រឹមត្រូវនៃឯកសារនេះត្រូវបានលោក សុខ ឥសាន អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជា បញ្ជាក់កាលពីម្សិលមិញ។

ទោះបីជាគណបក្សប្រជាជនកម្ពុជាបានរងការរិះគន់យ៉ាងខ្លាំងកាលពីឆ្នាំមុន ចំពោះការកាត់បន្ថយសេរីភាពបញ្ចេញមតិ និងការជួបជុំតាមរយៈច្បាប់ថ្មីរបស់ខ្លួនស្តីពីអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ថ្មីគ្រប់គ្រងសហជីពដែលនឹងចេញក្នុងពេលឆាប់ៗនេះក្តី? ក៏របាយការណ៍របស់ខ្លួនបានលើកឡើងអំពីច្បាប់ទាំងពីរនេះមកធ្វើជាឧទាហរណ៍បង្ហាញពីកំណែទម្រង់ប្រជាធិបតេយ្យបែបវិជ្ជមាន។

របាយការណ៍នេះមានខ្លឹមសារដូច្នេះថា "ការអនុវត្តច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលការត្រៀមរៀបចំច្បាប់សហជីព និងការពង្រឹងការអនុវត្តច្បាប់ស្តីពីឯកសារ និងនីតិវិធីនៅកម្ពុជាបានបង្ហាញយ៉ាងច្បាស់នូវចេតនាពិតរបស់រដ្ឋាភិបាលក្នុងការធានាសេរីភាពរបស់ប្រជាពលរដ្ឋគ្រប់រូបនៅក្នុងសង្គម។ ការកំណត់នយោបាយរបស់គណបក្សប្រជាជនកម្ពុជាបាននាំឱ្យមជ្ឈដ្ឋានជាតិ និងអន្តរជាតិវាយតម្លៃខ្ពស់ចំពោះការបោះជំហានឆ្ពោះទៅមុខក្នុងដំណើរការប្រជាធិបតេយ្យឱ្យរបស់កម្ពុជា"។ រដ្ឋាភិបាលកម្ពុជាបន្តជំរុញការអនុវត្តយ៉ាងសកម្មនូវកំណែទម្រង់ស៊ីជម្រៅ និងទូលំទូលាយ ដោយចាត់ទុកថាកំណែទម្រង់គឺជាកត្តាស្លាប់រស់សម្រាប់ប្រទេស"។

ការសន្យាធ្វើកំណែទម្រង់ទូលំទូលាយ គឺជាចំណុចផ្តោតដ៏សំខាន់របស់រដ្ឋាភិបាលគណបក្សប្រជាជនកម្ពុជា? ចាប់តាំងពីខ្លួនបានបាត់បង់សំឡេងគាំទ្រយ៉ាងច្រើនគួរឱ្យភ្ញាក់ផ្អើលនៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៣



លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងលោក ហេង សំរិន ប្រធានរដ្ឋសភា ចូលរួមក្នុងសន្និបាតគណៈកម្មាធិការកណ្តាលរបស់គណបក្សប្រជាជនកម្ពុជា នៅក្នុងរាជធានីភ្នំពេញកាលពីថ្ងៃសៅរ៍។ រូបថត: Khem Sovannara

និងការលេចឡើងវត្តមានរបស់គណបក្សសង្គ្រោះជាតិ ដែលធ្វើយុទ្ធនាការឃោសនាដោយសន្យាថា ខ្លួននឹងដំឡើងប្រាក់ឈ្នួល ហើយកាត់បន្ថយអំពើពុករលួយ។

របាយការណ៍ចេញពីសន្និបាតខាងលើលើកឡើងថា គោលនយោបាយអាទិភាពរបស់គណបក្សសម្រាប់ឆ្នាំ២០១៦ រួមមានកំណែទម្រង់ប្រព័ន្ធតុលាការការបង្កើនតម្លាភាព និងការកាត់បន្ថយអំពើពុករលួយផងដែរ ប៉ុន្តែវាស្ទើរតែគ្មានសេចក្តីលម្អិតអំពីបញ្ហាទាំងនេះ។ ផ្ទុយមកវិញ ភាគច្រើននៃរបាយការណ៍នេះលើកសរសើរចំពោះលទ្ធផលសេដ្ឋកិច្ចថ្មីៗនេះរបស់កម្ពុជា? ក្នុងនោះរួមមានទាំងការឡើងចំណាត់ថ្នាក់ពីប្រទេស "ដែលមានប្រាក់ចំណូលទាប" ទៅជាប្រទេស "ដែលមានប្រាក់ចំណូលក្រោមមធ្យម" ផងដែរ នេះបើយោងតាមការដាក់ចំណាត់ថ្នាក់របស់ធនាគារពិភពលោក។

ក្នុងផ្នែកមួយស្តីពីគោលនយោបាយការបរទេសរបាយការណ៍នេះបានគូសបញ្ជាក់អំពីស្ថាន

តទៅទំព័រទី២៣

# AT PARTY CONGRESS, CPP GIVES ITSELF TOP MARKS

byAunPheap | January 11, 2016

As senior members of the ruling CPP gathered in Phnom Penh this weekend for their annual congress, the party gave itself a glowing performance review and noted almost no areas for improvement, according to a 49-page report distributed to delegates at the two-day event.

The report praises the country's soaring economic growth and the passage of new legislation, while only briefly touching upon issues such as corruption and lack of transparency, other than to note the "life-or-death" importance of continued reform.

Although the CPP came under intense criticism last year for whittling away freedoms of expression and association with its new NGO law and an imminent new law governing labor unions, its report cites both as examples of positive democratic reform.

"The implementation of the Law on Associations and NGOs, the preparation of the union law and the strengthening of the implementation of the Law on Documents and Procedures in Cambodia has clearly shown the true intentions of the government in guaranteeing the freedom of all people in society," the report says.

"The political determination of the CPP has led national and international circles to fairly evaluate the steps forward in [Cambodia's] democratic process."

"The government of Cambodia continues to push active implementation of in-depth and wide reforms, with the consideration that reform is a life-and-death factor for the country," it adds.

Pledges of extensive reform have been the main focus of the CPP government since its shock near-loss in the 2013 national election and the rise of the opposition CNRP, which campaigns on promises that it will raise wages and reduce corruption.

The report from the congress says that the party's priorities for 2016 include judicial reform, increasing transparency and reducing corruption, but the document goes into almost no detail about these issues. Instead, the bulk of the document commends Cambodia's recent economic performance, including a projected upgrade from being a "low income" to a "lower middle income" country, according to World Bank rankings.

In a section on foreign policy, the report notes the deteriorating situation in the South China Sea and appears to blame the U.S. for creating a situation that could lead to conflict.

"In the South China Sea, the interference of great powers and some countries in demanding sovereignty in South China Sea has caused the situation to become increasingly complex," it says.

"The interference of great powers and some countries has tried to curb the growth of the People's Republic of China to [become] the largest power in the region and in the world, which could occur in the near future of the U.S.," the report adds.

"This point could cause armed clashes when some countries mount challenges with weapons in order to resolve the problem of the South China Sea with the People's Republic of China."

This weekend's event on KohPich island was the first party congress **Continued to Page 22**

ឌឺ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឺ ខេមបូឌា ដេលី

# វៀតណាម-កម្ពុជានឹងសម្ពោធបង្គោលព្រំដែន

**ដោយគុច ណារ៉េន** | **December 26, 2015**

យោងតាមលោកស្រី កុយ ពិសី អនុប្រធានគណៈកម្មាធិការកិច្ចការព្រំដែនកម្ពុជាបានឱ្យដឹងថា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងសមភាគីជនជាតិវៀតណាមរបស់លោក គឺលោក ង្វៀន តាន់យ៉ុង នឹងសម្ពោធបង្គោលព្រំដែនថ្មីចំនួនពីរកន្លែងនៅខេត្តរតនគិរី និងតាកែវនៅថ្ងៃសៅរ៍នេះ។

លោកស្រី ពិសី បានមានប្រសាសន៍ថា លោកនាយករដ្ឋមន្ត្រីនៃប្រទេសទាំងពីរនឹងចូលរួមពិធីនៅឯព្រំដែនខេត្តរតនគិរី និងខេត្តយ៉ាឡៃ នៅពេលព្រឹក ហើយចូលរួមម្តងទៀតនៅតាមព្រំដែននៃខេត្តតាកែវ និងខេត្តអាងយ៉ាងនៅពេលល្ងាច។

លោកស្រីបានមានប្រសាសន៍ថា បង្គោលព្រំដែននោះត្រូវបានបោះនៅក្បែរច្រកព្រំដែនអន្តរជាតិអូរយ៉ាដាវ និងនៅក្បែរច្រកព្រំដែនអន្តរជាតិភ្នំដិន។ លោកស្រីបានមានប្រសាសន៍បន្តថា ៨៣ភាគរយនៃព្រំដែនរួមគ្នាបានបោះបង្គោលព្រំដែនជាផ្លូវការរួចហើយ។

លោកស្រីបានមានប្រសាសន៍ថា "បងប្អូនជនរួមជាតិដឹងហើយថា កិច្ចការព្រំដែនគឺស្មុគស្មាញអ៊ីចឹងវាត្រូវការឯកភាពរវាងប្រទេសទាំងពីរ ព្រោះយើងចង់បានខ្សែព្រំដែនសុខសន្តិភាព និងសហប្រតិបត្តិការ"។ ការងាររបស់រដ្ឋាភិបាលក្នុងការបោះបង្គោលព្រំដែន និងការពារព្រំប្រទល់ភាគខាងកើតរបស់ខ្លួន គឺជាចំណុចកណ្តាលនៃយុទ្ធនាការគណបក្សប្រឆាំងកាលពីដើមឆ្នាំនេះ ដើម្បីលើកឡើងអំពីការទន្ទ្រានចូលព្រំដែនដោយប្រទេសវៀតណាមទៅក្នុងប្រទេសកម្ពុជា រួមមានការជីកស្រះមួយចំនួនដែលធ្វើឡើងដោយកសិករជនជាតិវៀតណាមនៅក្នុងខេត្តរតនគិរី។

ប្រព័ន្ធសារព័ត៌មានរដ្ឋវៀតណាមបានរាយការណ៍ថា ទីតាំងនៃបង្គោលព្រំដែនថ្មីទាំងពីរទទួលបានការយល់ព្រមក្នុងអំឡុងពេលជួបប្រជុំរបស់គណៈកម្មាធិការព្រំដែនរួមនៅក្នុងក្រុងភ្នំពេញកាលពីខែវិច្ឆិកា "ហើយការបោះបង្គោលព្រំដែនរវាងវៀតណាម និងកម្ពុជាជាបឋមបានចប់សព្វគ្រប់"។

ដោយដកស្រង់សម្តីលោក ង្វៀន អាញ់យ៉ុង អនុប្រធានគណៈកម្មាធិការព្រំដែននៃក្រសួងការបរទេសវៀតណាមអត្ថបទចេញផ្សាយក្នុងព័ត៌មានវៀតណាមនិយាយថា មានតំបន់ចំនួនប្រាំមួយកន្លែងតាមព្រំដែននៅក្នុងខេត្តរតនគិរី មណ្ឌលគិរី និងស្វាយរៀង នៅមិនទាន់មានការព្រមព្រៀងគ្នានៅឡើយទេ។

អត្ថបទព័ត៌មាននោះបានសរសេរថា "លោកបានចង្អុលបង្ហាញការលំបាកក្នុងការងារមានដូចជាការគ្រប់គ្រងព្រំដែនការប្រើផែនទីហួសសម័យ... ដែលខកខានមិនស៊ីចង្វាក់គ្នានឹងធាតុពិត ក៏ដូចជាមានសកម្មភាពវិទ្ធង្សនានៃកម្លាំងបក្សប្រឆាំងកម្ពុជាដើម្បីបំបែកបំបាក់មិត្តភាពទ្វេភាគី"។

លោក អ៊ុំ សំអាន តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិដែលស្ថិតនៅជួរមុខនៃកិច្ចប្រឹងប្រែង




របស់គណបក្សប្រឆាំងក្នុងការបង្ហាញភាពមិនត្រឹមត្រូវចំពោះការងារបោះបង្គោលព្រំដែនរាប់ទសវត្សរ៍របស់រដ្ឋាភិបាលជាមួយប្រទេសវៀតណាម បានមានប្រសាសន៍ថា បង្គោលថ្មីទាំងពីរបានរំលោភចូលទឹកដីកម្ពុជា។

លោក សំអាន ដែលឥឡូវនេះកំពុងរស់នៅក្រៅប្រទេសដោយខ្លាចអំពីការចាប់ខ្លួនពេលវិលត្រឡប់មកមាតុភូមិវិញ បានមានប្រសាសន៍ថា "ព័ត៌មានដែលយើងទទួលបានពីអ្នកភូមិគឺថាបង្គោលព្រំដែនសំខាន់លេខ៣០នៅក្នុងខេត្តរតនគិរីគឺបោះចូលជ្រៅទៅក្នុងដីខ្មែរ"។

អ្នកតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិរូបនេះបាននិយាយថា ទីតាំងនៃបង្គោលព្រំដែននៅក្នុងខេត្តតាកែវគឺធ្វើឡើងផ្អែកទៅតាមទីតាំងនៃប្រឡាយដែលជីកដោយវៀតណាមនៅក្នុងឆ្នាំ ១៩៧៩ ហើយវាមិនស្របគ្នាទៅនឹងផែនទីបារាំងដែលកំណត់ដោយរដ្ឋធម្មនុញ្ញដែលត្រូវយកមកកំណត់ព្រំដែននោះទេ។

លោកបាននិយាយបន្តថា "បង្គោលព្រំដែនគួរបោះដោយផ្អែកលើកេរដំណែលបារាំង គឺមិនមែនផ្អែកលើសន្ធិសញ្ញាធ្វើឡើងក្នុងទសវត្សរ៍ឆ្នាំ ១៩៨០នោះទេ ព្រោះកម្ពុជាបានស្ថិតនៅក្រោមការគ្រប់គ្រងរបស់វៀតណាម"។

លោកស្រី ពិសី បានមានប្រសាសន៍ថា លោក សំអាន និងអ្នកនយោបាយមានគំនិតប្រឆាំងគឺខុសហើយ។

លោកស្រីបានមានប្រសាសន៍ថា "ការលើកឡើងរបស់គេខ្ញុំបដិសេធថាមិនត្រឹមត្រូវទេ"៕

**រើន**

# VIETNAM, CAMBODIA TO INAUGURATE BORDER DEMARCATION POSTS

**by KuchNaren | December 26, 2015**

Prime Minister Hun Sen and his Vietnamese counterpart, Nguyen Tan Dung, will inaugurate two new border demarcation posts in the provinces of Ratanakkiri and Takeo on Saturday, according to KoyPisey, Cambodia's deputy chief of border affairs.

Ms. Pisey said the prime ministers would appear together at a ceremony on the border of Ratanakkiri and Gia Lai provinces in the morning, and again on the border of Takeo and An Giang provinces in the evening.

The posts have been planted near the O'Yadaw International Checkpoint in the country's northeast and near the Phnom Den International Checkpoint in the southeast, Ms. Pisey said, adding that 83 percent of the shared border had now been officially demarcated.

"As compatriots know, border affairs is very complicated, so it requires having agreements from the two countries because we plant border markers in order to transform frontiers into peaceful and harmonized borders," she said.

The government's work demarcating and protecting its eastern frontier was at the center of an opposition campaign earlier this year to highlight Vietnamese encroachments into Cambodia, including a series of ponds that Vietnamese farmers dug in Ratanakkiri.

Vietnamese state media reported that the locations of the two new border posts were agreed to during a meeting of the Joint Border Committee in Phnom Penh in November, and that the "demarcation between Viet Nam and Cambodia is basically completed."

Quoting Nguyen Anh Dung, deputy chairman of the Vietnamese Foreign Ministry's border commission, the article in Viet Nam News says there are six areas along the border in Ratanakkiri, Mondulkiri and Svay Rieng that remain contentious.

"He pointed out difficulties in the work such as border management, the use of old-fashioned maps…that fail to match realities, as well as Cambodia opposition forces' sabotage activities to divide bilateral friendship," the article says.

CNRP lawmaker Um Sam An, who has been at the fore of opposition efforts to discredit the government's decades of work demarcating the border with Vietnam, said the two new posts infringed upon Cambodian territory.

"The information we received from local villagers is that the key border marker No. 30 in Ratanakkiri province is planted deep inside Cambodia's land," said Mr. Sam An, who is living outside the country for fear that he will be arrested upon his return.

He said the position of the border marker in Takeo was based on the location of a canal dug by Vietnam in 1979, and was not consistent with the constitutionally mandated French maps that are supposed to determine demarcation.

"Border markers should be planted based on France's legacy, not based on a treaty made in the 1980s, because Cambodia was under Vietnam's control, " he said.

Ms. Pisey said Mr. Sam An and like-minded opposition politicians were wrong.

"Whatever they said, I deny it, because it is incorrect," she said.

ឌឹ ឃែមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ឃែមបូឌា ដេលី

# សម្បទានដីសេដ្ឋកិច្ចធំៗ

## កងទ័ពប្រជាជនវៀតណាមទទួលបានការគ្រប់គ្រងដីប្រហែល៤០.០០០ហិកតាយ៉ាងស្ងាត់ៗនៅក្នុងខេត្តរតនគិរី

**ដោយម៉ាតត៍ ប្លូមប៊ឹហ្គ និងវណ្ណ រឿន** |

**December 28, 2015**

ស្រុកអូរយ៉ាដាវ, ខេត្តរតនគិរី-គ្មាននរណាម្នាក់នៅទីនេះទំនងជាដឹងច្រើនអំពីក្រុមហ៊ុន៧២ទេ។ អ្នកភូមិដឹងថា ពួកគេកំពុងតែរស់នៅលើដីធ្លីដែលក្រុមហ៊ុនដាំដុះក្នុងដីសម្បទានសេដ្ឋកិច្ចដែលផ្តល់ឱ្យដោយរដ្ឋាភិបាល។ អ្នកភូមិមួយចំនួនធ្វើការងារកំប៉ិកកំប៉ុកដូចជា ការថែទាំដំណាំជាដើម ហើយគេឃើញព្រៃឈើដ៏ស្រស់បំព្រងត្រូវឈូសឆាយដើម្បីដាំដំណាំ ប៉ុន្តែលើសពីនេះទៅទៀត ក្រុមហ៊ុន៧២នៅតែជារឿងអាថ៌កំបាំង។

លោក ស៊ីវ វិញ ជាជនជាតិដើមភាគតិចចារ៉ាយ បាននិយាយកាលពីខែកញ្ញា ដោយក្រឡេកទៅមើលដីធ្លីមួយកន្លែងនៅក្នុងឃុំប៉ក់ញ៉ៃ ដែលកសិកររូបនេះបាននិយាយថា ជាកម្មសិទ្ធិប្រពន្ធរបស់គាត់រហូតដល់ក្រុមហ៊ុន៧២ចូលមកយកថា "យើងមិនដឹងប្រវត្តិក្រុមហ៊ុនទេ យើងមិនមានព័ត៌មានអ្វីទាំងអស់ គឺគ្រាន់តែស្គាល់ឈ្មោះប៉ុណ្ណោះ"។

**កសិករជាជនជាតិចារ៉ាយរូបនេះបាននិយាយថា "ពួកវៀតណាមចូលមកក្នុងឆ្នាំ២០១៣ហើយចាប់ផ្តើមឈូសឆាយ"។**

ប្រវត្តិនៃដីសម្បទានសេដ្ឋកិច្ចដែលមានទំហំ២០.០០០ហិកតានេះ គឺមានលក្ខណៈស្មុគស្មាញណាស់។ ដូច្នេះប្រវត្តិនៃដីសម្បទានសេដ្ឋកិច្ចបីកន្លែងផ្សេងទៀតក៏ស្មុគស្មាញដែរ គឺដីទាំងនេះលាតសន្ធឹងជាប់គ្នាតាមបណ្តោយព្រំដែន៣១គីឡូម៉ែត្រទៅតាមព្រំដែនវៀតណាម គឺស្ថិតនៅភាគពាយព្យ កាត់តាមស្រុកចំនួនបី និងចូលទៅក្នុងតំបន់កណ្តាលនៃខេត្តដាច់ស្រយាលនេះ។

ដំបូងឡើយ ត្រូវប្រគល់ដាច់ដោយឡែកពីគ្នាឱ្យក្រុមហ៊ុនកសិឧស្សាហកម្មបួនអស់រយៈពេលជាច្រើនឆ្នាំកន្លងមកនេះ ចាប់តាំងពីពេលនោះមក ដីសម្បទានសេដ្ឋកិច្ចបានធ្លាក់ចូលទៅក្នុងដៃបិញដួន១៥ ឬកងពល១៥ជាសាខានៃកងទ័ពប្រជាជនវៀតណាមដែលឈរជើងតាមព្រំដែនក្នុងខេត្ត ជា ឡៃ។

ក្រុមហ៊ុន៧២ គឺមិនមែនជាឈ្មោះនៃពាណិជ្ជកម្មទេ គឺជាកងឯកភាពកងទ័ព។ ហើយដីសម្បទានសេដ្ឋកិច្ចទាំងនោះ ដោយមានទំនាក់ទំនងយោធារបស់ខ្លួនគឺជាការពង្រីកនៃទឹកដីដែលគ្រប់គ្រងដោយវៀតណាម។

**តទៅទំព័រទី ១៩**



ផែនទីរបស់អង្គការលីកាដូដោយប្រើប្រាស់ទិន្នន័យផ្កាយរណបរបស់សហរដ្ឋអាមេរិកដែលចេញផ្សាយដោយសកលវិទ្យាល័យម៉ារីលែនបង្ហាញពីការកាប់បំផ្លាញព្រៃឈើនៅក្នុង និងជុំវិញដីសម្បទានចំនួនបួនគ្រប់គ្រងដោយកងទ័ពវៀតណាម។ ចំណុចបៃតងបង្ហាញពីគម្របព្រៃនៅសល់ចំណុចក្រហមបង្ហាញពីព្រៃដែលបានបាត់បង់ចន្លោះពីឆ្នាំ២០០០ដល់ឆ្នាំ២០១៤ រីឯចំណុច ពណ៌ខៀវបង្ហាញពីកំណើនព្រៃឈើថ្មីៗអំឡុងពេលនោះ។ Mark Tilly/The Cambodia Daily

# GRAND CONCESSIONS

## The Vietnamese People's Army has quietly assumed control of nearly 40,000 hectares of land in Ratanakkiri

BY MATT BLOMBERG AND VAN ROEUN

**December 24, 2015**

O'YADAW DISTRICT, Ratanakkiri province - Nobody here seems to know much about Company 72.

Locals know they are living on land the company cultivates under a government-granted economic land concession (ELC)-some have taken menial jobs tending the crops, all have seen lush forests decimated to make way for them-but beyond that, Company 72 remains mostly a mystery.




"We don't know the background of the company; we have no information, just the name," SevH'vinh, an ethnic Jarai farmer, said in September, looking out over a tract of land in Paknhai commune that he said belonged to his wife until Company 72 came along.

"The Vietnamese guys just arrived in 2013 and started bulldozing," he said.

The history of this 20,000-hectare ELC is complicated. So, too, are the histories of three other concessions, which, along with it, run end-to-end from a 31-km frontier along the Vietnamese border, northwest through three districts and into the heart of this farflung province.

Initially granted separately to four agribusiness ventures over the years, the concessions have since made their way into the hands of Binh Doan 15, or Corps 15, an arm of the Vietnamese People's Army stationed across the border in Gia Lai province.

Company 72 is not the name of a business; it is a military unit. And the concessions, with their military ties, are effectively an extension of territory controlled by Vietnam.

Documents obtained from government databases show that via a series of sales and transfers, this considerable swath of Ratanakkiri -39,584 hectares, an area larger than Kep province-is now controlled by Corps 15 commanders.

Three of the concessions are linked to the Vietnamese military via their chairmen, who are identified in Vietnamese state news reports as the heads of military units with names that correspond to the companies that have taken over the concessions. Pham Van Giang, for example, is both the chairman of AphivathCaoutchouc 72 Ratanakiri Co., Ltd., which has acquired the Rama Khmer concession, and the commander of the Vietnamese military's Company 72.

The fourth concession is not directly linked to the Vietnamese military via commanders and chairmen. However, Vietnamese state media has espoused Company 72's agricultural work and philanthropy on a military-controlled ELC in Bakeo district, the location of the CheaChanrith concession, which has been acquired in full by the firm AphivatCaoutchouc 72 OyaDav Co., Ltd.

"This is a concern," deputy provincial governor Nhem Sam Oeun said in a September interview, denying any previous knowledge of the Vietnamese military's control of the concessions. ELCs, he said, "are under the management of the Agriculture Ministry and Environment Ministry, and they have the right to look into this issue. I know nothing about the transfers."

As they are not inside protected areas, which are overseen by the Environment Ministry, the four concessions come under the purview of the Agriculture Ministry, **Continued to Page 20**

| Concession Holder | Veasna Investment Co., Ltd. | Chea Chanrith Aphivath Co., Ltd. | Rama Khmer International Co., Ltd. | Dai Dong Duong Commercial Joint Stock Company Co., Ltd. |
|---|---|---|---|---|
| Granted | June 26, 2007 | May 22, 2007 | February 12, 1996 | June 17, 2009 |
| Size | 5,080 hectares | 5,124 hectares | 20,000 hectares | 9,380 hectares |
| Crop | Rubber | Rubber | Rubber | Unknown |
| Resolutions | February 14, 2011 – New shareholder added, 75 Rattanakiri Co., Ltd New director, Do Van Sang, chairman of 75 Rattanakiri Co., Ltd. July 3, 2012 – All shares transferred to 75 Rattanakiri Co., Ltd. | April 23, 2012 – New shareholder added, Aphivat Caoutchouc 72 Oya Dav Co., Ltd, represented by Nguyen Canh Quang | February 9, 2012 – New shareholder added, Akphivath Caoutchouc Ratanak Kiri 72, represented by Pham Van Giang. New director, Pham Van Giang. All shares transferred to Akphivath Caoutchouc Ratanak Kiri 72. | August 20, 2012 – All shares transferred to Tran Quang Hung, chairman of Akphivath Caoutchouc 74 Ratanakiri Co., Ltd. |

ឌឺ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស    អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឺ ខេមបូឌា ដេលី

# បេឡាជាតិរបបសន្តិសុខសង្គមគ្រោងចាប់ផ្តើមគម្រោងគាំពារសុខភាពថ្មីសម្រាប់កម្មករនិយោជិត

**ដោយៈសេក ឧត្តម** | **January 7, 2016**

យោងតាមអនុក្រឹត្យដែលចេញកាលពីម្សិលមិញ និងចុះហត្ថលេខាដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានឱ្យដឹងថា គម្រោងគាំពារសុខភាពសម្រាប់កម្មករនិយោជិតបម្រើការងារស្របច្បាប់ទាំងអស់គ្រោងនឹងចាប់ផ្តើមដោយបេឡាជាតិរបបសន្តិសុខសង្គមរបស់រដ្ឋាភិបាលដោយសមាជិកទាំងអស់ត្រូវបានរ៉ាប់រងសម្រាប់ជំងឺគ្រប់មុខទាំងអស់។

បើទោះជាមានព័ត៌មានលម្អិតរួមទាំងពេលវេលាដែលគម្រោងនេះនឹងត្រូវអនុវត្តក៏ដោយ ក៏អនុក្រឹត្យនេះថែងថា បេឡាជាតិរបបសន្តិសុខសង្គមនឹងរ៉ាប់រងទៅលើការបាត់បង់ប្រាក់ឈ្នួលនៅថ្ងៃដែលខកខានធ្វើការដោយសារមានជំងឺផងដែរ។ អនុក្រឹត្យ ដដែលនេះបន្តថា និយោជិតទាំងអស់នឹងតម្រូវឱ្យបង់វិភាគទានប្រចាំខែចំពោះគម្រោងនេះ។

លោក ជាវ ប៊ុនរិទ្ធ អ្នកនាំពាក្យមូលនិធិនេះបានមានប្រសាសន៍ថា "កញ្ចប់គាំពារសុខភាពនេះគឺផ្តល់អត្ថប្រយោជន៍ដល់និយោជិតទាំងអស់តាមរយៈការព្យាបាល និងការពិគ្រោះជំងឺ។ វាមានអត្ថប្រយោជន៍ធំធេងចំពោះកម្មករនិយោជិតនៅពេលបេឡាជាតិរបបសន្តិសុខសង្គមផ្តល់ការធានារ៉ាប់រងគ្រោះថ្នាក់ដល់ពួកគេ"។

លោក ប៊ុនរិទ្ធ បានថ្លែងថា បច្ចុប្បន្នកម្មករនិយោជិតជាង១លាននាក់នៅតាមសហគ្រាសប្រហែល៨.000 ត្រូវបានចុះបញ្ជីជាមួយបេឡាជាតិរបបសន្តិសុខសង្គមដោយតម្លៃធានារ៉ាប់រងស្មើនឹង0.៨ភាគរយនៃប្រាក់ខែរបស់ពួកគេដែលត្រូវបង់ដោយនិយោជក និងរដ្ឋាភិបាល។

អនុក្រឹត្យដដែលនេះមានខ្លឹមសារថា កម្មករនិយោជិតនឹងតម្រូវឱ្យបង់ធានារ៉ាប់រងសម្រាប់កញ្ចប់គាំពារសុខភាព តែគេមិនបានផ្តល់តួលេខឡើយ ដោយនិយាយត្រឹមតែថា កម្មករនិយោជិតទាំងអស់នឹងបង់ "មិនច្រើនជាងនិយោជកទេ"។

លោក ប៊ុនរិទ្ធ បានថ្លែងថា "នៅថ្ងៃទី២១ ខែនេះ បេឡាជាតិរបបសន្តិសុខសង្គមនិយោជក និយោជិត និងរដ្ឋាភិបាលនឹងរៀបចំកិច្ចប្រជុំមួយដើម្បីពិភាក្សាថាតើនឹងតម្រូវឱ្យកម្មករនិយោជិតបង់វិភាគទានប៉ុន្មានចំពោះការគាំពារសុខភាព"។

លោកបានថ្លែងថា និយោជិតទាំងអស់ចាំបាច់ត្រូវបង់វិភាគទាន ប៉ុន្តែនិយោជកទេ ដែលនឹងបង់វិភាគទានច្រើនបំផុតនោះ"។

កាលពីម្សិលមិញមន្ត្រីសហជីព និងអ្នកតស៊ូមតិការងារបានសាទរគំនិតផ្តួចផ្តើមនេះ ដែលពួកគេលើកឡើងថាគួរតែធ្វើយូរមកហើយ ប៉ុន្តែបានលើកឡើងថា ពួកគេបារម្ភអំពីថា តើកម្មករនិយោជិតត្រូវបង់វិភាគទានប៉ុន្មាន ជាពិសេសនៅក្នុងវិស័យសេដ្ឋកិច្ចដែលក្នុងនោះ កម្មករនិយោជិតមានប្រាក់ឈ្នួលត្រឹមតែមួយគ្រប់ ដូចជាឧស្សាហកម្មកាត់ដេរដែលមានទឹកប្រាក់រាប់ពាន់លានដុល្លារជាដើម។

លោកស្រី យ៉ាង សុភ័ណ ប្រធានសម្ព័ន្ធសហជីពកម្ពុជាបានមានប្រសាសន៍ថា "រដ្ឋាភិបាលត្រូវគិតថាតើកម្មកររោងចក្រកាត់ដេរត្រូវលៃទុកប្រាក់ប៉ុន្មានដើម្បីបង់ឱ្យការគាំពារសុខភាព" ដោយស្នើឱ្យកម្មករ និយោជិតបង់មិនលើសពី៣0ភាគរយនៃថ្លៃធានារ៉ាប់រងដែលត្រូវបានសម្រេច។

លោកស្រីមានប្រសាសន៍ថា "និយោជកអាចចំណាយលើនិយោជិតរបស់ខ្លួនបានតាមរយៈការបង់នេះ។ ចំពោះពួកគេ វាមិនមែនជាបញ្ហាធំដុំទេ"។

លោក ប៉ាវ ស៊ីណា ប្រធានសម្ព័ន្ធសហជីពចលនាកម្មករបានមានប្រសាសន៍ថា លោកបានចូលរួមក្នុងកិច្ចប្រជុំពហុភាគីដើម្បីពិភាក្សាអំពីគម្រោងគាំពារសុខភាព ហើយបានព្យាករថា បេឡាជាតិរបបសន្តិសុខសង្គមនឹងតម្រូវឱ្យបង់ធានារ៉ាប់រងស្មើនឹង១ភាគរយនៃប្រាក់ខែគោល។

លោកបានមានប្រសាសន៍ថា "ពីមុន កម្មករនិយោជិតបង់១0ទៅ២0ដុល្លារ ប្រសិនបើពួកគេឈឺ។ ១ភាគរយគឺជាចំនួនតិចតួចសម្រាប់ការរ៉ាប់រងពេញ ប៉ុន្តែនិយោជកគួរទទួលខុសត្រូវបង់៨0ទៅ៩0ភាគរយ"។

លោក មឿន តុលា អ្នកតស៊ូមតិការងារដ៏ឆ្នើមមួយរូបដែលកាលពីសប្តាហ៍មុនបានចាប់ផ្តើមស្ថាប័នសិទ្ធិរបស់ខ្លួនផ្ទាល់ឈ្មោះថា Central បានចាត់ទុកគម្រោងគាំពារសុខភាពនេះថា ជាចំណាត់ការដ៏អស្ចារ្យរបស់រដ្ឋាភិបាល" ប៉ុន្តែបានព្រមានពីភាពលំបាកក្នុងការអនុវត្តឱ្យមានប្រសិទ្ធភាព។

លោកបានថ្លែងថា "សំណួរមួយគឺថា តើគុណភាពនៃសេវាកម្មរបស់បេឡាជាតិរបបសន្តិសុខសង្គម ដូចម្តេច" ដោយកត់សម្គាល់ថា កម្មករដែលមានរបួសទទួលបានការគាំពារក្រោមស្តង់ដារក្រោមគម្រោងរបស់បេឡាជាតិរបបសន្តិសុខសង្គមដែលមានស្រាប់នេះ។

លោកបានលើកឡើងថា "កម្មករនិយោជិតត្អូញត្អែរថា នៅពេលពួកគេបង្ហាញប័ណ្ណមូលនិធិបេឡាជិតរបបសន្តិសុខសង្គមដល់មន្ទីរពេទ្យគ្រូពេទ្យហាក់ដូចជាមិនយកចិត្តទុកដាក់ឱ្យបានគ្រប់គ្រាន់លើពួកគេឡើយ"។

លោកបានបន្ថែមថា "មន្ទីរពេទ្យទាំងអស់ក៏ត្អូញត្អែរផងដែរថា បេឡាជាតិរបបសន្តិសុខសង្គមយឺតយ៉ាវក្នុងការទូទាត់ប្រាក់ ដូច្នេះប្រហែលនេះជាមូលហេតុ" ដែលសមាជិកបេឡាជាតិរបបសន្តិសុខសង្គមទទួលបានការព្យាបាលមិនល្អនោះ៕

សារុន (រាយការណ៍ដោយ Matt Blomberg)

# NEW HEALTH CARE PLAN TO COVER WORKERS

**by Sek Odom | January 7, 2016**

A comprehensive health care plan for formally employed workers is set to be rolled out by the government's National Social Security Fund (NSSF), with members covered for all illnesses, according to a sub-decree released on Wednesday and signed by Prime Minister Hun Sen.

Though light on details, including when the plan will be implemented, the sub-decree states that the NSSF will also cover wages lost on work days missed due to sickness. Employees will be required to make a monthly contribution to the scheme, it says.

"This health care package is designed to benefit employees via treatment and consultations. It is a great benefit to the workers because at the moment the NSSF only provides them with [accident] insurance," said Chiev Bunrith, a spokesman for the fund.

Mr. Bunrith said more than 1 million workers at some 8,000 enterprises were currently registered with the NSSF, at a premium of 0.8 percent of their monthly salaries, which is paid by employers and the government.

The sub-decree states that workers themselves will be required to pay a premium for the health care package, though it offers no figures, saying only that workers will pay "not more than employers."

"On the 21st of this month, the NSSF, employers, employees and the government will hold a meeting to discuss what contributions [workers will be required to make] toward health care," Mr. Bunrith said.

"The employees will need to make a contribution, but it is the employers who will make the greatest contribution," he said.

Unionists and labor advocates on Wednesday applauded the initiative, which they described as long overdue, but said they worried about how much workers would be made to contribute, particularly in sectors of the economy in which the workers earn hand-to-mouth wages, such as the multibillion-dollar garment industry.

"The government has to think about how much money garment workers have to spare to pay toward [health care]," said YaingSophorn, president of the Cambodian Alliance of Trade Unions, suggesting that workers should be required to pay no more than 30 percent of whatever premium is decided on.

"The employer can invest in their employees by paying for this. For them, it's not a big deal," she said.

PavSina, head of the Collective Union of Movement of Workers, said he had participated in multiparty meetings to discuss the heath care plan, and predicted that the NSSF would require premiums equal to 1 percent of base wages.

"Before, workers would pay $10 to $20 if they got ill. One percent is a small amount for full coverage but the employers should be responsible for 80 to 90 percent of that," he said.

Moeun Tola, a prominent labor advocate who last week launched his own rights organization, Central, described the health care plan as "a great move by the government" but warned of potential difficulties in carrying it out effectively.

"One question is how would the quality of the NSSF service be," he said, noting that injured workers routinely received substandard care under the existing NSSF scheme.

"Workers complain that when they show the NSSF card at the hospital, doctors don't seem to care enough about them," he said.

"Hospitals also complain that the NSSF is slow to process [payments], so maybe that is a reason" NSSF members receive poor treatment.

**(Additional reporting by Matt Blomberg)**

# មីកឆេលវូ (Michelle Wu) បានបង្កើតនៅប្រវត្តិសាស្ត្រថ្មី

**រៀបរាងដោយ : តារាយុទ្ធ ហង្ស**

មីកឆេវូរ ដែរមានអាយុ៣០ឆ្នាំនឹងជាកូនកាត់ចិន-អាមេរិក បានរៀនចប់នៅសាលាច្បាប់ហាវីដ (Havardlaw school) នឹងជាអតីតម្ចាស់






Michelle Wu makes history as City Council president The 30-year-old Roslindale lawyer ascended to the rostrum after serving just one term.

ភោគនិយដ្ឋានមេធាវីផ្តល់សេវាផ្នែកច្បាប់ ហើយក៏ជាស្ត្រីអាស៊ីដំបូងដែរ ជាប់ជាក្រុមប្រឹក្សា ឥឡូវនេះបានឡើងទទួលតំណែងជាប្រធានក្រុមប្រឹក្សាយោបល់ទីក្រុងប៊ូស្តុន(Boston)ការពីថ្ងៃច័ន្ទ ទី៤ ខែមករា ឆ្នាំ២០១៦។ នៅពេលសុន្ទរកថា ទទួលតំណែងរបស់នាង អ្នកស្រី វូ បានស្វាគមន៏ក្រុមសមាជិកប្រឹក្សាថ្មីពីរនាក់គឺ AnnissaEssaibi George ដែរបានឈ្នះកៅអីដ៏ច្រើន នឹង Andrea Joy Campbell ដែរឥលូវនេះជាតំណាង សង្កាត់ទី៤ (District 4) មុននឹងគូសបញ្ជាក់ពីរបៀបវារៈ។ នាងបានជំរុញសហសេវិករបស់នាងឱ្យផ្តោតទៅលើការកាត់បន្ថយភាពមិនស្មើភាពគ្នានៃចំណូលនឹងការកែទំរង់ប្រព័ន្ធយុត្តិធមិបទឧក្រិដ្ឋ (Criminal Justice System) នឹងការពង្រីងនៃឱកាសនៃការអប់រំ។ នាងក៏បានមានប្រសាសន៏ថែមទៀតថា "ខ្ញុំពិតជាដឹងគុណចំពោះឱកាសទាំងអស់ដែរ ខ្ញុំបានទទួល ហើយខ្ញុំត្រៀមខ្លួនជាស្រេចដើម្បីដោះស្រាយនូវបញ្ហាដែរកើតឡើងចំពោះទីក្រុង ហើយនាងក៏បន្ថែមទៀតខ្ញុំពិតជាសប្បាយចិត្តណាស់ដែរបានមានឱកាសអង្គុយពិភាក្សាជាមួយអ្នករាល់គ្នាក្នុងការស្វែងរកគំនិតល្អៗក្នុងការជួយនូវទីក្រុងរបស់ពួកយើង៕

## Michelle Wu, the first Chinese and Asian tescend was elected as Council President of Boston

**By Soben Pin**

Boston - January 4th, 2016, Michelle Wu, the first Chinese and Asian tescend was elected as Council President. Mayor Walsh and Senator Elizabeth Warren also were in attended and spoke. As Council President, Wu spoke goalsfor the next term - transparency and accessibility is first and foremost and vowed to work on reducing income inequality, reforming our criminal justice system, improving educational opportunities, and preparing for climate change. Below is the information background I found from Michelle Wu's campaign website at www. michelleforboston.com

**About Michelle**

My name is Michelle Wu. In 2013, I was elected as a Boston City Councilor At-Large. I am running for re-election because I believe in Boston. I believe we can lead as a national model of an inclusive innovation economy that connects all of our neighborhoods and communities. I believe we can serve as an example of an urban public education system that creates meaningful pathways for all our students, and I believe that all of this depends on a foundation of strong, vibrant, local engagement in each of our neighborhoods.

**Photo Credit: Jovan**

I have gotten to know and love the sense of community and family that Boston's neighborhoods represent. From advising entrepreneurs at the WilmerHale Legal Services Center in Jamaica Plain, to working with survivors of domestic violence at the Medical-Legal Partnership at Boston Medical Center and health centers around the city, I have seen the power of community organizations serving city residents. As legal guardian of my youngest sister, I have chaired the School Site Council for the Eliot K-8 School in the North End and volunteered with the Boston Latin Home and School Association. Prior to serving

**Continued to Page 23**



**CONWAY**
**INSURANCE AGENCY**

**រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវ៉េយបានបម្រើសហគមន៏ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងលែន ។**

**យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :**

**ការធានារ៉ាប់រងគ្រួសារ**
- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្ការ
- វត្ថុសិល្បះ
- វត្ថុបុរាណ

**ការធានារ៉ាប់រងជំនួញ**
- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- វិកខ៏ខម (Worker's Compensation)
- បនដស៏ (Bonds)
- អ្នកមើលថែឡាន និងការ៉ាស់ឡាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេងៗទៀត

CONWAY INSURANCE AGENCY

77 E. Merrimack Street. Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com
សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង

Allstate.
You're in good hands.



**Veasna Chhay**
Licensed Sales Producer
Home/Auto/Life MA & RI

**Allstate Insurance Company**
1535 Smith Street
North Providence, RI 02911

Phone 508-282-5820/Cell 401-588-4358
veasnachhay2@allstate.com

*Personalized service.*
*Trusted advice.*

" Also I do income tax return service for MA and RI for "Veasna Tax Preparation Serivices'."

**ការងារ ! ការងារ! ការងារ!**

ត្រូវការអ្នកបកប្រែជាភាសាខ្មែរនៅសាលារដ្ឋដែលស្ថិតនៅ Lynn និង Revere ។

ដោយចាប់ផ្តើមដំបូងក្នុងមួយម៉ោង២០ដុល្លារ ។ ដោយមិនចាប់បាច់ត្រូវការនូវសញ្ញាប័ត្រនោះទេ ។

បើសិនជាចាប់អារម្មណ៏សូមមេត្តាទាក់ទងទៅកាន់ទូរស័ព្ទ
**978-594-4695** ឬក៏ផ្ញើអ៊ីម៉ែលទៅកាន់
**Jim@CityGateLs.com**

**JOBS! JOBS! JOBS!**

Khmer Interpreters needed for Public Schools in Lynn and Revere.
We pay $20.00 per hour to start. No certifications required.
**Please call 978-594-4695 or email jim@CityGateLS.com**

តមកពីទំព័រទី ១៦

# ដីសម្បទានសេដ្ឋកិច្ចធំៗ...

ឯកសារទាំងឡាយដែលទទួលបានពីទិន្នន័យរដ្ឋាភិបាលបង្ហាញថា តាមរយៈការលក់ដូរ និងការផ្ទេរកម្មសិទ្ធិ ដីធ្លីដែលមានទំហំធំគួរសមនៃខេត្តរតនគិរី គឺទំហំ៣៩.៥៨៤ហិកតា ជាទំហំដីដែលធំជាងខេត្តកែបទៅទៀត គឺឥឡូវនេះគ្រប់គ្រងដោយពួកមេបញ្ជាការកងពល១៥។

មានដីសម្បទានសេដ្ឋកិច្ចចំនួនបីជាប់ទាក់ទងនឹងយោធាវៀតណាម តាមរយៈប្រធានរបស់គេ ដែលបង្ហាញអត្តសញ្ញាណនៅក្នុងរបាយការណ៍ព័ត៌មានរដ្ឋវៀតណាមថា ជាមេបញ្ជាការកងឯកភាពយោធាដែលមានឈ្មោះត្រូវគ្នាទៅនឹងក្រុមហ៊ុនដែលគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច។ ជាឧទាហរណ៍លោក ផាំ វ៉ាន់ជាំង (Pham Van Giang) គឺជាប្រធាននៃក្រុមហ៊ុនអភិវឌ្ឍន៍កៅស៊ូក៧២ រតនគិរី (AphivathCaoutchouc 72 Rata-na-kiri Co., Ltd) ដែលទទួលបានដីសម្បទានសេដ្ឋកិច្ចរ៉ាម៉ាខ្មែរ និងជាមេបញ្ជាការនៃកងអនុសេនាធំ៧២នៃយោធាវៀតណាម។

ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចទី៤ គឺមិនមានការជាប់ទាក់ទងផ្ទាល់ទៅនឹងយោធាវៀតណាម តាមរយៈមេបញ្ជា និងប្រធានក្រុមហ៊ុននោះទេ។ ទោះជាយ៉ាងនេះក្តីសារព័ត៌មានរដ្ឋវៀតណាមបានលើកឡើងអំពីការងារកសិកម្ម និង-កិច្ចការមនុស្សធម៌របស់កងអនុសេនាធំ៧២ទៅលើដីសម្បទានសេដ្ឋកិច្ចដែលគ្រប់គ្រងដោយយោធានៅក្នុងស្រុកបរកែវ ជាទីតាំងនៃដីសម្បទានសេដ្ឋកិច្ចជា ចាន់រិទ្ធិ ដែលទទួលបានពេញលេញដោយក្រុមហ៊ុនអភិវឌ្ឍន៍កៅស៊ូក៧២អូរយ៉ាដាវ (Aphivat Caoutchouc 72 OyaDav Co., Ltd)។

លោក ញ៉ែម សំអឿន អភិបាលរងខេត្តបានមានប្រសាសន៍នៅក្នុងខែកញ្ញា ដោយបដិសេធថា លោកមិនបានដឹងអំពីប្រវត្តិនៃការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ចដោយយោធាវៀតណាមថា "នេះជាការព្រួយបារម្ភ"។ លោកអភិបាលរងខេត្តរូបនេះ បានមានប្រសាសន៍ថា "គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម និងក្រសួងបរិស្ថាន ហើយគេមានសិទ្ធិពិនិត្យមើលរឿងនេះ។ ខ្ញុំមិនដឹងអំពីការផ្ទេរទេ"។

ដោយសារតែដីសម្បទានសេដ្ឋកិច្ចទាំងនេះមិនស្ថិតនៅក្នុងតំបន់ការពារដែលមើលការខុសត្រូវដោយក្រសួងបរិស្ថាន ដីសម្បទានសេដ្ឋកិច្ចទាំងបួននេះស្ថិតក្រោមការគ្រប់គ្រងដោយក្រសួងកសិកម្មដែលបានផ្តល់និងទទួលខុសត្រូវលើការត្រួតពិនិត្យក្រុមហ៊ុនទាំងនេះ។ នៅក្នុងកិច្ចសម្ភាសន៍មួយនៅឯការិយាល័យរបស់លោក កាលពីខែវិច្ឆិកា លោក អ៊ាង សុផល្លែត អ្នកនាំពាក្យក្រសួងកសិកម្មបានទទួលយកឯកសារដែលរៀបរាប់អំពីវិធីដែលដីសម្បទានសេដ្ឋកិច្ចនៅក្នុងខេត្តរតនគិរី ត្រូវគ្រប់គ្រងដោយយោធាវៀតណាម។

លោក សុផល្លែត បានមានប្រសាសន៍ដោយសុំឱ្យអ្នកយកព័ត៌មានកុំទាន់ចុះផ្សាយព័ត៌មានទាក់ទងនឹងដីសម្បទានសេដ្ឋកិច្ច ទម្រាំគណៈកម្មាធិការរដ្ឋាភិបាលបញ្ចប់ការសើរើដីសម្បទានសេដ្ឋកិច្ចទាំងអស់ទូទាំងប្រទេសជាមុនសិនថា "វាមិនទាន់ដល់ពេលសម្រាប់ខ្ញុំក្នុងការឆ្លើយ ឬទទួលស្គាល់ថា ក្រុមហ៊ុនទាំងបួននេះស្ថិតនៅក្រោមកងទ័ពវៀតណាមនោះទេ"។

អ្នកនាំពាក្យក្រសួងកសិកម្មរូបនេះមានប្រសាសន៍ថា "ខ្ញុំទទួលឯកសារទាំងនេះពីលោក ប៉ុន្តែខ្ញុំមិនទាន់បានពិនិត្យផ្ទៀងផ្ទាត់គណៈកម្មាធិការមិនទាន់បានពិនិត្យផ្ទៀងផ្ទាត់ដែរ"។



យោធាវៀតណាមមិនបានឆ្លើយតបទៅនឹងសំណើជាច្រើនលើកច្រើនសាសុំការធ្វើអត្ថាធិប្បាយទេ។ លេខទូរស័ព្ទដែលចុះបញ្ជីដោយក្រសួងពាណិជ្ជកម្មសម្រាប់ក្រុមហ៊ុនទាំងឡាយដែលគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ចគឺមិនដំណើរការ ឬមិនមានអ្នកទទួលទូរស័ព្ទ។

កាលពីខែឧសភា ឆ្នាំ២០១២ លោក-នាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាឱ្យបញ្ឈប់ការផ្តល់ដីសម្បទានសេដ្ឋកិច្ចថ្មី ដោយសារតែមានរបាយការណ៍ទាក់ទិននឹងការរំលោភបំពានកិច្ចសន្យា ព្រៃឈើ និងប្រជាពលរដ្ឋមូលដ្ឋានកាន់តែកើនឡើង។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាឱ្យពិនិត្យសើរើលើដីសម្បទានសេដ្ឋកិច្ចទាំងអស់ ហើយយោងតាមលោក សុផល្លែត ឱ្យដឹងថា ការផ្ទេរនិងការលក់ដូរគឺជាការខុសច្បាប់។ ទោះជាយ៉ាងនេះក្តីអ្នកនាំពាក្យរូបនេះបានមានប្រសាសន៍ថា មានលក្ខខណ្ឌមួយអនុញ្ញាតឱ្យម្ចាស់ដីសម្បាទានដែលមានស្រាប់ "ស្វែងរកដៃគូដើម្បីចូលរួមអភិវឌ្ឍ"។

ពាណិជ្ជកម្មភាគច្រើនដែលបញ្ចូលដីសម្បទានសេដ្ឋកិច្ចខេត្តរតនគិរីទៅក្នុងដៃកងទ័ពប្រជាជនវៀតណាម បានកើតឡើងក្នុងរយៈពេលច្រើនខែមុននឹងមានការផ្អាកការផ្តល់ដីសម្បទានសេដ្ឋកិច្ច។

ទោះជាយ៉ាងនេះក្តីរយៈពេលពីរខែបន្ទាប់ពីការផ្អាកនោះមកនៅក្នុងខែកក្កដា ឆ្នាំ២០១២ យោងតាមឯកសារក្រសួងពាណិជ្ជកម្មឱ្យដឹងថា ភាគហ៊ុនទាំងអស់នៅក្នុងដីសម្បទានបួនកន្លែងនៅភាគខាងជើងបង្អស់ គឺក្រុមហ៊ុនវាសនា អ៊ិនវេសមិន ត្រូវបានប្រគល់ឱ្យក្រុមហ៊ុនមួយមានឈ្មោះថា ៧៥រតនគិរី ខូអិលធីឌី ដែលមានប្រធានឈ្មោះថា ដូ វ៉ាន់សាង (Do Van Sang) ដែលបង្ហាញអត្តសញ្ញាណនៅក្នុងរបាយការណ៍ព័ត៌មានរដ្ឋវៀតណាម? ថាជាមេបញ្ជាការកងអនុសេនាធំ៧៥។

បន្ទាប់មកនៅក្នុងខែសីហាក្នុងឆ្នាំដដែលនោះ ដីសម្បទានសេដ្ឋកិច្ច ដាយ ដុងយឿង ដែលនៅជាប់នឹងព្រំដែនបានផ្ទេរភាគហ៊ុនទាំងអស់របស់ខ្លួនទៅឱ្យ ទ្រឹន ខ្វាង ហាន់ (Tran Quang Hang) ដែលកាលពីមុនជាម្ចាស់ភាគហ៊ុនភាគតិច ដែលមានឈ្មោះនៅក្នុងប្រព័ន្ធផ្សព្វផ្សាយរដ្ឋវៀតណាមថាជាមេបញ្ជាការកងអនុសេនាធំ៧៤។

លោក សុផល្លែត បានមានប្រសាសន៍ថា ដីសម្បទានសេដ្ឋកិច្ច ដាយ ដុងយឿង នឹងត្រូវវាយតម្លៃ "នៅក្នុងប៉ុន្មានសប្តាហ៍ខាងមុខទៀតនេះ" ចំណែកឯការវាយតម្លៃជាទូទៅដែលដឹកនាំដោយឧបនាយករដ្ឋមន្ត្រី ប៊ិន ឈិន នឹងបញ្ចប់នៅក្នុងរយៈពេល "យ៉ាងច្រើនពីរខែ"។ អ្នកនាំពាក្យក្រសួងកសិកម្មរូបនេះ បានមានប្រសាសន៍ថា ក្រុមអធិការកិច្ចកំពុងពិនិត្យមើលដើម្បីបញ្ជាក់ថា ម្ចាស់ដីសម្បទានគោរពច្បាប់ភូមិបាល និងអនុវត្តតាមកិច្ចព្រមព្រៀងរបស់គេក្នុងពេលដែលចូលរួមវិភាគទានក្នុងការអភិវឌ្ឍកម្ពុជា ប៉ុន្តែនឹងមិនផ្តោតលើប្រភពនៃវិនិយោគទេ។

លោក សុផល្លែត បានមានប្រសាសន៍ថា "តាមខ្ញុំដឹងយើងមិនរើសអើងចំពោះកងទ័ព អ្នកជំនួញ ស្ថាប័ន ឬប្រទេសណាមួយទេ។ យើងស្វាគមន៍រាល់វិនិយោគទាំងអស់នៅកម្ពុជា។ ប្រទេសនីមួយៗមានអធិបតេយ្យភាពរបស់ខ្លួន ប្រទេសនីមួយៗមាននីតិរដ្ឋរបស់ខ្លួន ហើយនរណាក៏ដោយអាចធ្វើវិនិយោគនៅក្នុងប្រទេសត្រូវតែគោរពច្បាប់។? ហើយប្រសិនបើអ្នកមិនគោរពច្បាប់ទេ យើងនឹងមានវិធានការយើងនឹងចាត់វិធានការ"។

យោងតាមអង្គការសិទ្ធិមនុស្សលីកាដូឱ្យដឹងថា ឥឡូវនេះ ដោយមានផ្ទៃដីជាង២.១៤លានហិកតា ដីសម្បទានសេដ្ឋកិច្ចគ្របដណ្តប់ទៅលើផ្ទៃដីជាងពាក់កណ្តាលនៃផ្ទៃដីអាចដាំដុះបានរបស់ប្រទេសកម្ពុជា ដោយមាន៥៧ភាគរយនៃផ្ទៃដីនោះគ្រប់គ្រងដោយក្រុមហ៊ុនបរទេស។

ទទួលរងនូវការរិះគន់យ៉ាងខ្លាំងពីសំណាក់មជ្ឈដ្ឋានក្នុង និងក្រៅប្រទេសដោយសារតែការផ្តល់ដីសម្បទានដ៏ធំធេងនោះ លោក ហ៊ុន សែន បានផ្តល់ទឡ្ហីករណ៍ថា ដីសម្បទានសេដ្ឋកិច្ច គឺត្រូវការជាចាំបាច់ "ដើម្បីអភិវឌ្ឍប្រទេសជាតិ" ដោយពន្យល់ថា ផលប្រយោជន៍ជាក់ស្តែង រួមមានការងារ ផ្លូវថ្នល់ សាលារៀនដែលដីសម្បទានទាំងនោះនាំមកឱ្យសហគមន៍ទាំងឡាយដែលរស់នៅតំបន់នោះ។

ប៉ុន្តែការពិតសម្រាប់ប្រជាពលរដ្ឋដែលរស់នៅក្នុង ឬនៅក្បែរដីសម្បទានសេដ្ឋកិច្ចនៅក្នុងខេត្តរតនគិរី? ដែលភាគច្រើនជាជនជាតិដើមភាគតិចប្រកបរបរចិញ្ចឹមជីវិតផ្អែកទៅលើព្រៃព្រឹក្សា គឺមានលក្ខណៈផ្ទុយគ្នាទៅវិញ។

អស់រយៈពេលជាច្រើនឆ្នាំកន្លងមកក្រុមអង្គការសិទ្ធិមនុស្ស និងអ្នកយកព័ត៌មានមានរបាយការណ៍ជាច្រើនទាក់ទិននឹងបណ្តឹងរំលោភបំពានប្រឆាំងនឹងក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចទាំងបួនដែលទន្ទ្រានយកដីសហគមន៍បំផ្លិចបំផ្លាញព្រៃអ្នកតា និងកន្លែងកប់សពការកាប់ឈើដោយខុសច្បាប់នៅខាងក្រៅព្រំប្រទល់របស់ខ្លួន និងការនាំចេញឈើប្រណិតដោយខុសច្បាប់ឆ្លងកាត់តាមច្រករបៀងព្រំដែនជាមួយប្រទេសវៀតណាម។

លោក ឆាយ ធី អ្នកសម្របសម្រួលអង្គការសិទ្ធិមនុស្សអាដហុកប្រចាំខេត្តរតនគិរីបាននិយាយថា "មានផលប៉ះពាល់ច្រើនដោយមិនមានដំណោះស្រាយគ្រប់គ្រាន់ទេ"។

លោក ឆាយ ធី ដែលចំណាយពេលភាគច្រើនរបស់លោកតាមដានការបាត់បង់ព្រៃឈើនៅក្នុងខេត្តនេះ បានមានប្រសាសន៍ថា ការកាប់ឈើខុសច្បាប់នៅក្នុងនិងជុំវិញដីសម្បទានសេដ្ឋកិច្ចទាំងបួននេះ បានកើតឡើងនៅក្នុងឆ្នាំ២០១២ និង ២០១៣ ក្រោយពីយោធាវៀតណាមគ្រប់គ្រងតំបន់នោះ។

លោក ឆាយ ធី បានមានប្រសាសន៍ថា "ឈ្មួញវៀតណាមរកស៊ីឈើ ខ្លះមកតាមរយៈក្រុមហ៊ុន ហើយខ្លះឃុបឃិតជាមួយក្រុមហ៊ុន"។

ឥឡូវនេះខណ្ឌកាត់តំបន់ដ៏ធំនេះជាពីរដែលស្ថិតក្រោមការគ្រប់គ្រងរបស់យោធាវៀតណាម គឺផ្លូវជាតិលេខ៧៨ ដែលលាតសន្ធឹងពីក្រុងបានលុងទៅកាន់បន្ទាយកងអនុសេនាធំ៧២ និងកងអនុ-សេនាធំ៧៤ កាត់តាមព្រំដែន គឺមានចម្ងាយ១៦

តទៅទំព័រទី ២១

Continued from page 16

# GRAND CONCESSIONS...

which granted and is responsible for monitoring them. In an interview at his office in November, EangSophalleth, a spokesman for the Agriculture Ministry, was presented with the documents outlining how the concessions in Ratanakkiri had come to be run by the Vietnamese military.

"It would be too premature for me to answer or to acknowledge that these four companies are under the Vietnamese army," Mr. Sophalleth said, asking reporters to refrain from publishing an article about the concessions until an intergovernmental committee completed a review of all concessions in the country.

"I have these documents from you but I have not verified [them], the committee has not verified [them]," he said.

The Vietnamese military did not respond to numerous requests for comment. The numbers listed by the Commerce Ministry for the companies that control the concessions were either not in use, or calls went unanswered.

In May 2012, Prime Minister Hun Sen ordered a stop to the granting of new concessions as reports of abuse-of contracts, forests and local people-mounted. Mr. Hun Sen ordered a review of all concessions and, according to Mr. Sophalleth, outlawed transfers and sales. However, one caveat allows existing concessionaires to "find partners to join the development," he said.

Much of the trading that consolidated the Ratanakkiri concessions in the hands of the Vietnamese People's Army occurred in the months leading up to the moratorium. However, two months after it, in July 2012, according to Commerce Ministry filings, all shares in the northernmost of the four concessions, Veasna Investment, were handed over to a firm named 75 Rat-tanakiri Co., Ltd., whose chairman, Do Van Sang, is identified in Vietnamese state news reports as commander of Company 75.

Then, in August of the same year, the border-hugging Dai Dong Duong concession had all of its shares transferred to Tran Quang Hang, previously a minority shareholder, who is named in Vietnamese state media as the commander of Company 74.

Mr. Sophalleth said the Dai Dong Duong concession was due to be assessed "in the next few weeks," while the overall evaluation, led by Deputy Prime Minister Bin Chhin, would be completed in a "maximum of two months." Inspectors are looking to certify that concessionaires are obeying the Land Law and honoring their agreements while contributing to the development of Cambodia, he said, but would not focus on the source of investment.

"As I know, we do not discriminate between army, business people, institutions or any countries at all. We welcome all investment in Cambodia," Mr. Sophalleth said. "Each country has its own sovereignty, each country has its own rule of law, and whoever invests in the country must respect it. And if you don't respect it, we have to take measures, we have to take actions."

**(Mark Tilly/The Cambodia Daily)**

Totaling more than 2.14 million hectares, ELCs now cover more than half of Cambodia's arable land, with 57 percent of that area controlled by foreign firms, according to rights group Licadho. Under heavy criticism for the mass sell-off, both locally and from abroad, Mr. Hun Sen has argued that ELCs are needed to "develop the country," explaining the ostensible benefits-jobs, roads, schools-that they bring to the communities on which they are imposed.

But the reality for people living on or near the concessions in Ratanakkiri-many of them members of indigenous minorities whose lives revolve around the forests-is quite the opposite.

Over the years, rights groups and reporters have fielded a litany of abuse complaints against the four concessions: encroaching on communal land, destroying spirit forests and burial grounds, logging outside their boundaries, and illegally exporting luxury-grade timber across the porous border with Vietnam.

"There are a lot of impacts without adequate solutions," said Chhay Thy, provincial coordinator for rights group Adhoc.

Mr. Thy, who spends much of his time monitoring the province's disappearing forests, said that logging in and around the four concessions peaked in 2012 and 2013, shortly after the Vietnamese military took control of them.

"Vietnamese dealers made a business of timber; some came through the companies and some connived with the companies," he said.

Bisecting the giant swath of land now under the control of the Vietnamese military is National Road 78, which runs from the provincial capital of Banlung City to the barracks of Company 72 and Company 74 across the border, just 16 km and 26 km, respectively, from the O'Yadaw International Checkpoint.

Trucks and motorbikes loaded with luxury wood flow freely across the O'Yadaw checkpoint, though with timber baron Try Pheap's special economic zone just down the road, only a few kilometers inside Cambodian territory, the ownership and legality of the hauls remains unclear.

Satellite imagery also shows that inside the Dai Dong Duong concession, there are dozens of roads, tracks and trails crossing the border.

"It is easy for them to go back and forth, shipping timber across the border," Mr. Thy said.

Reporters visiting remote Ratanakkiri villages in and around the concessions in September were received mostly by smiling children and welcoming elders. In the secluded village of Krieng, however, an uneasiness filled the air. Children scuttled out of sight, mothers shut doors, and men glanced around the village, seemingly searching for reasons why visitors might be there.

About 15 km off an arterial road running through Bakeo district, Krieng is an island in a sea of cleared forest and rubber plantations-all of it inside the CheaChanrith concession, chaired by the commander of Company 72 since April 2012.

"The land clearing started here in 2009 and reached the edge of our village," said RochamMoum, who previously led a losing campaign against the pillaging of the forest around the village.

The mood in Krieng, Mr. Moum said, was the result of his ethnic Tampoun community having had its identity stolen away. The forest had provided them not only with food and raw materials for shelter -it had been the resting place of their ancestors, whose spirits are believed to live on in the trees.

When the trees were cleared all the way to the edge of Krieng, Mr. Moum said, their once fervent advocacy group was disbanded. "We no longer have a forestry community because we have no forest left to protect," he said.

The community in Krieng is not unique, however, particularly in provinces such as Ratanakkiri with dense and potentially lucrative forests.

Environmental watchdogs have for years been highlighting the potential revenue disappearing across the border in vehicles filled with timber, and the havoc wrought on indigenous communities as they watch the forests fall around them. Opposition politicians have campaigned heavily this year against alleged violations of Cambodia's sovereignty from the east, focusing on a series of irrigation ponds dug by Vietnamese people about 500 meters into Cambodian territory on the Dai Dong Duong concession. (Much of the border area here is designated a "white zone," having not been properly demarcated, meaning that neither side is allowed to occupy or use the land.)

Cambodia's Foreign Ministry delivered a terse statement in June demanding that Hanoi have the ponds filled in. Hanoi promised to oblige, but, according to the opposition's latest dispatch earlier this month, has not made good on its pledge.

A visit to an informal checkpoint just a few hundred meters from the ponds demonstrated how in this part of the country, the line between Cambodia and Vietnam can be blurred.

A Cambodian woman selling Vietnamese-labeled snacks and drinks out of a tin shack at the border had hanging in her shop a framed portrait of her young son, dressed in a Vietnamese police uniform and photoshopped onto a tropical beach.

